ខុមហ្វ្រែល COMFREL

# របាយការណ៍
# សង្កេតរដ្ឋសភា និងតំណាងរាស្ត្រ

## របាយការណ៍ឆ្នាំទី២ នីតិកាលទី៦ (២០១៩-២០២០)

ប្រៀបធៀបសកម្មភាពតំណាងរាស្ត្រចុះមូលដ្ឋាន








ខែមីនា ឆ្នាំ ២០២១

# មាតិកា


សង្ខេបការរកឃើញ .......................................................................................... 1

វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យសម្រាប់ចងក្រងរបាយការណ៍ .................................... 3

របាយការណ៍ស្តីពី ការសង្កេតរដ្ឋសភាជាតិ.............................................................. 5

១. ដំណើរការសម័យប្រជុំនៃរដ្ឋសភា................................................................... 5

២.ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ......................................................... 17

៣. គណៈកម្មការជំនាញនៃរដ្ឋសភា .................................................................. 26

៤.ការវិភាគសកម្មភាពរបស់តំណាងរាស្ត្រ........................................................... 32

៥.សកម្មភាពរបស់តំណាងរាស្ត្រក្នុងស្ថានភាពកូវីដ-១៩ ....................................... 37

៦. កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗ នៃរដ្ឋសភាជាតិ ............................................. 37

Vision: A democratic society where democratization in particular democratic elections are promoted and qualified to bring benefit to people.

ថ្ងៃអង្គារ ២រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការសង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី២ នីតិកាលទី៦

ជាឆ្នាំបន្តនូវនីតិកាលទី៦ របស់ខ្លួនដោយមិនមានអាសនៈនៃគណបក្សផ្សេង។ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានដំណើរការទៅដោយរលូន ទាំងសកម្មភាពការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ ដំណើរការរបស់គណៈកម្មការជំនាញ សកម្មភាពសម័យប្រជុំពេញអង្គរបស់រដ្ឋសភា និងការអនុម័តច្បាប់។

ឆ្នាំទី២ នៃនីតិកាលទី៦នេះ ខុមហ្វ្រែល សង្កេតឃើញថា មានអ្នកតំណាងរាស្ត្រកើនជាងឆ្នាំមុនក្នុងការឡើងបញ្ចេញមតិ និងនាទីនៃការឡើងបញ្ចេញមតិក្នុងសម័យប្រជុំពេញអង្គក៏កើនឡើងផងដែរ។ ចំណែកការចុះមូលដ្ឋានហាក់មិនសូវផុសផុលដូចឆ្នាំទី១ទេ ទោះបីចំនួនតំណាងរាស្ត្រកើនក្នុងការចុះបេសកកម្មក៏ដោយ តែចំនួនលើកនៃការចុះបេសកកម្មបានថយចុះ នេះបើធៀបជាមួយឆ្នាំទី១ នៃអាណត្តិជាមួយគ្នា(តំណាងរាស្ត្រម្នាក់ជាមធ្យមចុះបាន **១៩លើក** ក្នុងឆ្នាំទី១ និង **៩លើក** ក្នុងឆ្នាំទី២)។ ការកើនចំនួនតំណាងរាស្ត្រចុះ និងថយចុះចំនួនបេសកកម្មទៅមូលដ្ឋាននេះ អាចនិយាយបានថា មកពីតំណាងរាស្ត្រគិតគូពីសុខទុក្ខប្រជាពលរដ្ឋ ទាក់ទងនឹងស្ថានភាពនៃការរីករាលដាលការឆ្លងជំងឺកូវីដ១៩ ។ សម័យប្រជុំរបស់រដ្ឋសភាក្នុងឆ្នាំទី២ នេះ មានរបៀបវារៈកើនឡើងជាងឆ្នាំទី១ តែចំនួនកិច្ចប្រជុំបានថយចុះ។ ការប្រជុំរបស់រដ្ឋសភា ខុមហ្វ្រែលបានសង្កេតឃើញថា ភាគច្រើននៃការឡើងបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រគឺ ការកោតសរសើរលើច្បាប់ ការសរសើរដល់រាជរដ្ឋាភិបាលដែលបានផ្តួចផ្តើមឱ្យមានច្បាប់ ជាជាងការជជែកពីបញ្ហាខ្វះខាតនៃច្បាប់ ឬលើកបញ្ហាដែលបានកើតមានចំពោះច្បាប់ដែលបានអនុវត្តកន្លងមក។

គណៈកម្មការជំនាញទាំង១០របស់រដ្ឋសភា ក្នុងឆ្នាំងទី២ ខុមហ្វ្រែលមើលឃើញថា មិនសូវសកម្មដូចឆ្នាំទី១ទេ ហើយក៏មិនមានការកោះហៅសមាជិករដ្ឋាភិបាលណាមួយមកសាកសួរ ឬឆ្លើយបំភ្លឺពីបញ្ហាកើតមានពីការអនុវត្តច្បាប់ ឬផលប៉ះពាល់ដែលកើតមានចំពោះប្រជាពលរដ្ឋដែរ នេះបើធៀបជាមួយឆ្នាំទី១ នៃអាណត្តិជាមួយគ្នា។

ជារួម នៅក្នុងឆ្នាំទី២ នៃនីតិកាលទី៦នេះ ខុមហ្វ្រែលបានសង្កេតឃើញថា ប្រសិទ្ធភាពសភាឯកបក្សនៅតែមិនមានការវិវដ្តឱ្យប្រសើរជាងឆ្នាំទី១ ឬអាណត្តិកន្លងមកឡើយ ព្រោះខុមហ្វ្រែលនៅតែមិនឃើញមានការចេញលិខិត

អន្តរាគមន៍របស់តំណាងរាស្ត្រ មិនឃើញមានអ្នកតំណាងរាស្ត្រនិយាយពីភាពអសកម្មក្នុងការដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ សកម្មភាពសួរដេញដោលលើការអនុវត្តិច្បាប់ ការជជែកវែកញែកលើសេចក្តីស្នើ ឬសេចក្តីព្រាងច្បាប់នៅក្នុងសម័យប្រជុំរដ្ឋសភា រួមទាំងការបង្កើតច្បាប់ដោយភាពចម្រូងចម្រាសផងដែរ។

**ដំណើរការសម័យប្រជុំនៃរដ្ឋសភា៖** រដ្ឋសភាបានចាប់ផ្តើមសម័យប្រជុំដំបូងរបស់ខ្លួននៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៩ ក្រោមការដឹកនាំផ្ទាល់របស់សម្តេច ហេង សំរិន ប្រធានរដ្ឋសភាជាតិ។ ក្នុងឆ្នាំទី២នេះ រដ្ឋសភាបានបើកសម័យប្រជុំពេញអង្គបានចំនួន **៩ដង** ដោយសម្រេចបាននូវរបៀបវារៈចំនួន**៣៩**របៀបវារៈ។ ក្នុងសម័យប្រជុំរបស់រដ្ឋសភា ខុមប្រែ្ហល សង្កេតឃើញមានតំណាងរាស្ត្រចំនួន **១៤រូប** បានឡើងបញ្ចេញមតិបានចំនួន **៣៨ដង** គិតជាថិរវេលាមានចំនួន **២៤១នាទី** បើគិតពីចំនួនអ្នកតំណាងរាស្ត្រ និងរយៈពេល គឺច្រើនជាង បើប្រៀបធៀបជាមួយឆ្នាំទី១ នៃអាណត្តិជាមួយគ្នានេះ។

**ភាពចម្រូងចម្រាសនៃច្បាប់៖** បើទោះជាមានភាពរលូនក្នុងការអនុម័តនូវច្បាប់នានារបស់តំណាងរាស្ត្រក្នុងអង្គប្រជុំរដ្ឋសភាក៏ដោយ តែមានច្បាប់ពីរដែលមិនទាន់បានសិក្សាពីធាតុចូលឱ្យស៊ីជម្រៅជាមួយភាគីពាក់ព័ន្ធនៅឡើយ តែរដ្ឋសភាបានអនុម័តចេញយ៉ាងប្រញ៉ាប់ និងដាក់ឱ្យអនុវត្ត រួមមាន៖

1. សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា បំពេញបន្ថែមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។
2. ការអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

**ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ៖** ក្នុងឆ្នាំទី២ នៃនីតិកាលទី៦នេះ ក្នុងចំណោមតំណាងរាស្ត្រ ១២៥រូប មានតែអ្នកតំណាងរាស្ត្រ ១០៤រូបប៉ុណ្ណោះ ដែលមានសកម្មភាពចុះមូលដ្ឋាន។ សកម្មភាពចុះមូលដ្ឋាននេះ គឺបានចំនួន ៨៩៩ លើក ដែលចំនួននេះ គិតជាមធ្យមគឺអ្នកតំណាងរាស្ត្រ១រូប ចុះបេសកកម្មបាន ០៩លើក។

ក្នុងចំណោមបេសកកម្មចំនួន ***៨៩៩លើក*** មាន ***៨៤.៤ភាគរយ*** គឺជាការចុះសួរសុខទុក្ខ និងសំណេះសំណាល និងសម្តែងការកោតសរសើរចំពោះអាជ្ញាធរមូលដ្ឋាន។ ទោះជាយ៉ាងណា ខុមប្រែ្ហល បានសង្កេតឃើញមានការចុះអន្តរាគមន៍ និងចូលរួមវេទិកាផងដែរ។

តំណាងរាស្ត្រមិនមែនត្រឹមតែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ គឺជាតំណាងប្រជាពលរដ្ឋទូទាំងប្រទេស។ តាមការសង្កេត តំណាងរាស្ត្របានចុះគ្រប់ ២៥រាជធានី/ខេត្ត ក្នុងនោះមាន **២១៨លើក** ជាបេសកកម្មនៅក្រៅមណ្ឌល និង **៦៨១លើក**ជាបេសកកម្មនៅក្នុងមណ្ឌល។

**គណៈកម្មការជំនាញនៃរដ្ឋសភា៖** តាមការសង្កេតរបស់ខុមប្រែ្ហល ឃើញថា ការចុះបេសកម្មទៅមូលដ្ឋានរបស់គណៈកម្មការជំនាញសរុបបានចំនួន **៥៥ដង**។ ក្នុងចំណោមគណៈកម្មការជំនាញទាំង១០ របស់រដ្ឋសភា មានតែគណៈកម្ម

ការជំនាញចំនួន ៨ប៉ុណ្ណោះដែលបានចុះទៅមូលដ្ឋាន ហើយគណៈកម្មការជំនាញដែលមិនបានចុះមូលដ្ឋានគឺ គណៈកម្មការទី៤ និងទី៥។ ក្នុងចំណោមគណៈកម្មការដែលបានធ្វើបេសកកម្មទៅមូលដ្ឋាន មានតែ២គណៈកម្មការប៉ុណ្ណោះ ដែលមានបេសកកម្មលើសពី១០(ដប់)ដង គឺគណៈកម្មការជំនាញទី៣ និង គណៈកម្មការទី៨។

បេសកកម្មរបស់គណៈកម្មការជំនាញចុះមូលដ្ឋាន ភាគច្រើនក្នុងគោលបំណងចុះសិក្សាស្វែងយល់ពីការអនុវត្តិការងាររបស់អាជ្ញាធរ និងសួរសុខទុក្ខប្រជាពលរដ្ឋគឺ មានចំនួន ៥១លើក រីឯការចូលរួមក្នុងវេទិកា ឬកិច្ចប្រជុំបានចំនួន២លើក ការចុះពង្រឹងបណ្តាញបក្សគឺ បានចំនួន១លើក និងចុះអមដំណើរថ្នាក់ដឹកនាំបានចំនួន១លើកប៉ុណ្ណោះ។

ខុមហ្វ្រែល សង្កេតឃើញថា ពុំមានគណៈកម្មការជំនាញណាមួយ បានធ្វើការកោះហៅសមាជិករាជរដ្ឋាភិបាលមកសាកសួរនោះទេ ទោះបីជាមានបញ្ហាអយុត្តិធម៌ដែលបានកើតឡើងយ៉ាងច្រើននៅក្នុងសង្គមខ្មែរក៏ដោយ ជាពិសេសបញ្ហាដីធ្លី ការកាប់ព្រៃឈើ ការប្រើប្រាស់កងកម្លាំងដើម្បីបង្ក្រាបទៅលើប្រជាពលរដ្ឋក៏ដោយ។ល។

**ការវិភាគសកម្មភាពតំណាងរាស្ត្រ៖** ខុមហ្វ្រែលបានជ្រើសរើសសកម្មភាពរបស់តំណាងរាស្ត្រទាំង១០រូប ដែលមានភាពសកម្មជាងគេតាមការសង្កេតក្នុងសម័យប្រជុំរដ្ឋសភា និងការចុះមូលដ្ឋាន។ ជាលទ្ធផលបានបង្ហាញថា ក្នុងឆ្នាំទី២នេះ តំណាងរាស្ត្រដែលមានតួនាទីជាសមាជិករដ្ឋាភិបាល ឬតួនាទីក្រៅពីស្ថាប័នរដ្ឋសភាបានចុះបេសកកម្មតិចតួចដែលខុសពីឆ្នាំទី១នៃអាណត្តិជាមួយគ្នា គឺមានតំណាងរាស្ត្រមានតួនាទីក្នុងរដ្ឋាភិបាល ឬតួនាទីក្រៅពីរដ្ឋសភាបានចុះបេសកកម្មទៅមូលដ្ឋានច្រើន។ រីឯការបញ្ចេញមតិយោបល់ក្នុងសម័យប្រជុំរដ្ឋសភាទៀតសោត តំណាងរាស្ត្រដែលមានមុខតំណែងក្នុងរដ្ឋាភិបាលបានបញ្ចេញមតិតិចតួច ឬមិនមានទាល់តែសោះ។


***សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖***

១. លោក គឹម ឈន     នាយកប្រតិបត្តិ     ០១២ ៩៤២ ០១៩

២. លោក កន សាវាង្ស     អ្នកសម្របសម្រួលផ្នែកអង្កេត និងតស៊ូមតិ ០១១ ៨៨៤ ៨៤០

# សង្ខេបការរកឃើញ

ឆ្នាំទី២ អាណត្តិទី៦នេះ ខុមហ្វ្រែលសង្កេតឃើញថា គណៈកម្មការជំនាញរដ្ឋសភាមិនសូវមានភាពសកម្មទេ ចំណែកក្នុងសម័យប្រជុំនីមួយៗមានការឡើងបញ្ចេញមតិច្រើនដែរពីសំណាក់តំណាងរាស្ត្រ បើធៀបជាមួយឆ្នាំទី១ គឺមានការកើនឡើងទាំងចំនួនតំណាងរាស្ត្រ និងទាំងចំនួននាទីដែលតំណាងរាស្ត្របានបញ្ចេញមតិ។ សកម្មភាពទៅមូលដ្ឋានឯណោះវិញ ឃើញថា ចំនួនតំណាងរាស្ត្រចុះមូលដ្ឋានមានការកើនឡើង តែចំនួននៃការចុះមូលដ្ឋានបានធ្លាក់ចុះ នេះបើធៀបជាមួយឆ្នាំទី១នៃអាណត្តិជាមួយគ្នា។

**ដំណើរការសម័យប្រជុំនៃរដ្ឋសភា៖** រដ្ឋសភាបានចាប់ផ្តើមសម័យប្រជុំពេញអង្គដំបូងរបស់ខ្លួននៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៩ ក្រោមការដឹកនាំផ្ទាល់របស់សម្តេច ហេង សំរិន ប្រធានរដ្ឋសភាជាតិ។ ក្នុងឆ្នាំទី២នេះ រដ្ឋសភាបានបើកសម័យប្រជុំពេញអង្គបានចំនួន **៩ដង** ដោយសម្រេចបាននូវរបៀបវារៈចំនួន**៣៩**។

ក្នុងសម័យប្រជុំរបស់រដ្ឋសភា ខុមហ្វ្រែល សង្កេតឃើញមានតំណាងរាស្ត្រចំនួន **១៤រូប** បានឡើងបញ្ចេញមតិបានចំនួន **៣២ដង** គិតជាថិរវេលាមានចំនួន**២៤១នាទី** បើគិតពីចំនួនអ្នកតំណាងរាស្ត្រ និងរយៈពេលច្រើនជាង បើប្រៀបធៀបជាមួយឆ្នាំទី១ នៃអាណត្តិជាមួយគ្នានេះ។

**ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ៖** ក្នុងឆ្នាំទី២ នៃនីតិកាលទី៦នេះ ក្នុងចំណោមតំណាងរាស្ត្រ១២៥រូប មានតែអ្នកតំណាងរាស្ត្រ **១០៤រូប**ប៉ុណ្ណោះ ដែលមានសកម្មភាពចុះមូលដ្ឋាន។ សកម្មភាពចុះមូលដ្ឋាននេះ គឺបានចំនួន **៨៩៩លើក** ដែលចំនួននេះ គិតជាមធ្យមគឺអ្នកតំណាងរាស្ត្រម្នាក់ចុះបេសកកម្មបាន **០៩លើក**។

ខុមហ្វ្រែល បានចែកការចុះបេសកកម្មរបស់តំណាងរាស្ត្រក្នុងគោលបំណងចំនួន ៥ធំ។ ក្នុងចំណោមបេសកកម្ម**៨៩៩លើក**នេះ **៨៤.៤ភាគរយ** គឺជាការចុះសួរសុខទុក្ខ និងសំណេះសំណាល និងសម្តែងការកោតសរសើរចំពោះអាជ្ញាធរមូលដ្ឋាន។ ទោះជាយ៉ាងណា ខុមហ្វ្រែល បានសង្កេតឃើញមានការចុះអន្តរាគមន៍ និងចូលរួមវេទិកាផងដែរ។

តំណាងរាស្ត្រមិនមែនត្រឹមតែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួនទេ គឺតំណាងប្រជាពលរដ្ឋទូទាំងប្រទេស។ តាមការសង្កេត តំណាងរាស្ត្របានចុះគ្រប់២៥រាជធានីខេត្ត ក្នុងនោះមាន **២១៨លើក**ជាបេសកកម្មនៅក្រៅមណ្ឌល និង **៦៨១លើក**ជាបេសកកម្មនៅក្នុងមណ្ឌល។

**គណៈកម្មការជំនាញនៃរដ្ឋសភា៖** តាមការសង្កេតរបស់ខុមហ្វ្រែល ឃើញថា ការចុះបេសកម្មទៅមូលដ្ឋានរបស់គណៈកម្មការជំនាញសរុបបានចំនួន **៥៥លើក**។ ក្នុងចំណោមគណៈកម្មការជំនាញទាំង១០របស់រដ្ឋសភា មានតែគណៈកម្មការជំនាញចំនួន៨ប៉ុណ្ណោះ ដែលបានចុះទៅមូលដ្ឋាន ហើយគណៈកម្មការជំនាញដែលមិនបានចុះមូលដ្ឋានមាន គឺគណៈកម្មការទី៤ និងទី៥។ ក្នុងចំណោមគណៈកម្មការដែលបានធ្វើ

បេសកកម្មទៅមូលដ្ឋាន មានតែ២គណៈកម្មការប៉ុណ្ណោះ ដែលមានបេសកកម្មលើសពី **១០(ដប់)លើក** គឺ គណៈកម្មការជំនាញទី៣ និង គណៈកម្មការទី៨។

បេសកកម្មរបស់គណៈកម្មការជំនាញចុះមូលដ្ឋាន ភាគច្រើនក្នុងគោលបំណងចុះសិក្សាស្វែងយល់ និងសួរសុខទុក្ខដែលមានចំនួន**៥១លើក**។ ការចុះសិក្សាស្វែងយល់នេះគឺ ចុះជួបជាមួយប្រជាពលរដ្ឋ និង អាជ្ញាធរមូលដ្ឋានដើម្បីចូលរួមសិក្សាស្វែងយល់ពីបញ្ហានានា ដូចជាការអនុវត្តច្បាប់ និងការឆ្លើយតបដោយមានភាពឃើតយ៉ាវរបស់អាជ្ញាធរជាមួយប្រជាពលរដ្ឋ។

ខុមហ្វ្រែលក៏សង្កេតឃើញថា ពុំមានគណៈកម្មការជំនាញណាមួយ បានធ្វើការកោះហៅសមាជិករាជរដ្ឋាភិបាលមកសាកសួរនោះទេ បើទោះជាមានបញ្ហាអយុត្តិធម៌ដែលបានកើតមានឡើងយ៉ាងច្រើននៅក្នុងសង្គមខ្មែរក៏ដោយ ជាពិសេសប្រជាពលរដ្ឋដែលរងគ្រោះដោយបញ្ហាដីធ្លី ការកាប់ព្រៃឈើ ការប្រើប្រាស់កងកម្លាំងហួសហេតុក្នុងការដេញប្រជាពលរដ្ឋនាំឱ្យមានរងរបួសដោយការអនុវត្តិសាលដីការបស់តុលាការជាដើម។ល។

**ការវិភាគសកម្មភាពតំណាងរាស្ត្រ៖** ខុមហ្វ្រែលបានជ្រើសរើសសកម្មភាពរបស់តំណាងរាស្ត្រទាំង១០រូប ដែលមានភាពសកម្មជាងគេតាមការសង្កេតក្នុងសម័យប្រជុំរដ្ឋសភា និងការចុះមូលដ្ឋាន។ ជាលទ្ធផលបានបង្ហាញថា ក្នុងឆ្នាំទី២នេះ តំណាងរាស្ត្រដែលមានតួនាទីជាសមាជិករដ្ឋាភិបាល ឬតួនាទីក្រៅពីស្ថាប័នរដ្ឋសភាបានចុះបេសកកម្មតិចតួច ដែលខុសពីឆ្នាំទី១នៃអាណត្តិជាមួយគ្នា គឺមានតំណាងរាស្ត្រមានតួនាទីក្នុងជួររដ្ឋាភិបាល ឬតួនាទីក្រៅពីរដ្ឋសភាបានចុះបេសកកម្មទៅមូលដ្ឋានច្រើន។ រីឯការបញ្ចេញមតិយោបល់ក្នុងសម័យប្រជុំរដ្ឋសភាទៀតសោត តំណាងរាស្ត្រដែលមានមុខតំណែងក្នុងរដ្ឋាភិបាលបានបញ្ចេញមតិតិចតួច ឬមិនមានទាល់តែសោះ។

## សន្និដ្ឋាន

ខុមហ្វ្រែល សង្កេតឃើញថា នៅក្នុងឆ្នាំទី២ នៃនីតិកាលទី៦នេះ អ្នកតំណាងរាស្ត្រចុះមូលដ្ឋានហាក់មិនសូវផុសផុលដូចឆ្នាំទី១ទេ ចំនួនតំណាងរាស្ត្រកើនក្នុងការចុះ តែចំនួននៃការចុះបានថយចុះ នេះបើធៀបជាមួយឆ្នាំទី១ (ឆ្នាំទី១តំណាងរាស្ត្រ៥៥រូប បានចុះមូលដ្ឋានបានរហូតដល់**១០៤១លើក** រីឯឆ្នាំទី២នេះវិញ គឺមានតំណាងរាស្ត្រដល់**១០៤រូប** បានចុះមូលដ្ឋានតែចំនួន**៨៩៩លើក**ប៉ុណ្ណោះ) ការកើនចំនួនតំណាងរាស្ត្រទៅមូលដ្ឋាននេះអាចនិយាយបានថា មកពីតំណាងរាស្ត្រគិតគូពីសុខទុក្ខប្រជាពលរដ្ឋក្នុងស្ថានភាពកូវីដក៏ថាបាន។ ការសំណេះសំណាលជាមួយប្រជាពលរដ្ឋ អមដំណើរថ្នាក់ដឹកនាំ ពង្រឹងផ្ទៃក្នុងរបស់គណៈបក្ស មានចំនួនផុសផុល ការចូលរួមវេទិកា(កាលឆ្នាំទី១ពុំមាន តែឆ្នាំទី២នេះឃើញមាន) ហើយការចុះជួយអន្តរាគមន៍ដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋក៏ឃើញមានដែរក្នុងឆ្នាំទី២នេះ ដែលខុសពីឆ្នាំទី១

គឺពុំមានទាល់តែសោះ។ ដោយឡែក ចំពោះសម័យប្រជុំពេញអង្គឯណោះវិញ រដ្ឋសភាបានបើកសម័យប្រជុំទាំងសាមញ្ញសាធារណៈ និងវិសាមញ្ញសាធារណៈ ក្នុងនោះភាគច្រើនគឺផ្តោតលើការអនុម័តច្បាប់។ អ្វីដែលគួរឱ្យកត់សម្គាល់ ក៏ដូចជាការសង្កេតឃើញរបស់ខុមហ្វ្រែល គឺការឡើងបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រមានការកើនឡើង (តំណាងរាស្ត្រឡើងបញ្ចេញមតិក្នុងសម័យប្រជុំរដ្ឋសភាមានចំនួន១៤រូប បញ្ចេញមតិបាន**២៩ដង** គិតជានាទីបានចំនួន**២៤១នាទី** លើសឆ្នាំទី១ដែលមានតែ ១២រូប បញ្ចេញមតិបាន**៣៩ដង** សរុបនាទីបាន**២០៩នាទី**ប៉ុណ្ណោះ)។ បើទោះជាមានការកើនឡើងមែន តែការអនុម័តនូវច្បាប់នានាមិនឃើញមានតំណាងរាស្ត្រណាម្នាក់ឡើងបញ្ចេញមតិជំទាស់ រិះគន់ ឬសួរដេញដោលឡើយ ដោយជំនួសមកវិញមានតែការសសើរ និងគាំទ្រដល់ការដឹកនាំរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះ។ ការយកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋ ដូចជាការខ្វះខ្វែងការពារយុត្តិធម៌ ការពារផលប្រយោជន៍ និងភាពជាតំណាងក្នុងកិច្ចការផ្សេងៗ សម្រាប់ប្រជាពលរដ្ឋ ឃើញមានតំណាងរាស្ត្រចុះជួយអន្តរាគមន៍ដោះស្រាយ ប៉ុន្តែ បញ្ហាដែលកើតមានក្នុងសង្គមរាប់មិនអស់ដែលមន្ត្រីមានសមត្ថកិច្ចអនុវត្តមិនត្រឹមត្រូវតាមច្បាប់ មិនបានបំពេញតម្រូវការឱ្យសមស្របសម្រាប់ប្រជាពលរដ្ឋ ហើយបានធ្វើឱ្យខូចខាត ប៉ះពាលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋទាំងដែលប្រជាពលរដ្ឋស្រែកដង្ហើយសុំឱ្យជួយរកយុត្តិធម៌សម្រាប់ពួកគាត់ក៏ដោយ ក៏ពុំឃើញមានកោះហៅសមាជិករាជរដ្ឋាភិបាលណាមួយមកសួរឆ្លើយបំភ្លឺឡើយ។

ជារួម ក្នុងឆ្នាំទី២ នៃនីតិកាលទី៦នេះ ខុមហ្វ្រែលសង្កេតឃើញថា ប្រសិទ្ធភាពរដ្ឋសភាមិនមានភាពប្រសើរឡើយ ។ ប្រសិទ្ធិភាពនៃការធ្លាក់ចុះនេះ ក៏ព្រោះតែរដ្ឋសភាឯកបក្សមិនបានដោះស្រាយបញ្ហាជាតិឱ្យបានជាដុំកំភួនដូចជាបញ្ហាព្រំដែនជាមួយវៀតណាម បញ្ហាពលរដ្ឋនៅស្ទើរគ្រប់ទីកន្លែង តែមិនឃើញមានតំណាងរាស្ត្ររូបណាដាក់លិខិតកោះហៅសមាជិករដ្ឋាភិបាលមកបំភ្លឺ ពេលប្រជុំពេញអង្គម្តងៗមិនឃើញមានអ្នកតំណាងរាស្ត្រនិយាយពីភាពអវិជ្ជមាន ឬអសកម្មក្នុងការអនុវត្តច្បាប់ដើម្បីដោះស្រាយបញ្ហាជូនពលរដ្ឋរបស់រាជរដ្ឋាភិបាល តំណាងរាស្ត្រមិនបានសួរដេញដោល វែកញែក បញ្ចេញមតិឱ្យស្វាហាប់ដើម្បីបំពេញភាពចន្លោះប្រហោងនៅក្នុងការបង្កើតច្បាប់នីមួយៗឡើយ។ ហេតុនេះ បានជាធ្វើឱ្យប្រសិទ្ធភាពរដ្ឋសភាទាំងមូលមានការធ្លាក់ចុះ។

## វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យសម្រាប់ចងក្រងរបាយការណ៍

ដើម្បីបានទិន្នន័យចងក្រងជារបាយការណ៍នេះ ខុមហ្វ្រែលមានវិធីសាស្ត្រប្រមូលដូចជា៖ ដាក់មន្ត្រីតាមដាន និងសង្កេតដំណើរការនៃការប្រព្រឹត្តទៅរបស់រដ្ឋសភារួមមាន សម័យប្រជុំរដ្ឋសភា ការឡើងបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ ការប្រមូលសកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ឬការចុះអន្តរាគមន៍របស់អ្នកតំណាងរាស្ត្រ សកម្មភាពរបស់គណៈកម្មការជំនាញជាដើម។

វិធីសាស្ត្រក្នុងការប្រមូលនូវព័ត៌មានដែលពាក់ព័ន្ធសកម្មភាពរបស់តំណាងរាស្ត្រមានដូចជា៖

១. ខុមហ្វ្រែល បានបញ្ជូនមន្ត្រី ឬអ្នកស្ម័គ្រចិត្តរបស់ខ្លួនទៅធ្វើការសង្កេតដោយផ្ទាល់នៅក្នុងសម័យប្រជុំនីមួយៗ (ដំណើរការនៃសម័យប្រជុំរដ្ឋសភា និងការឡើងបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ)។

២. ស្រង់យកព័ត៌មានតាមរយៈគេហទំព័ររបស់រដ្ឋសភា ប្រភពសារព័ត៌មាន បណ្ដាញព័ត៌មានសង្គម ហ្វេសប៊ុកគណៈបក្សតាមខេត្តនីមួយៗ និងហ្វេសប៊ុកផេកផ្ទាល់ខ្លួនរបស់តំណាងរាស្ត្រ ដើម្បីប្រមូលនូវសកម្មភាពចុះមូលដ្ឋានរបស់គណៈកម្មការជំនាញនៃរដ្ឋសភា និងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ។

សកម្មភាពក្នុងចំណុចទី២ គឺជាការកែប្រែនីតិវិធីក្នុងការប្រមូលព័ត៌តាមរយៈការចុះដោយផ្ទាល់នៅមូលដ្ឋានជាមួយអ្នកតំណាងរាស្ត្រ ឬការប្រមូលព័ត៌មាននៅការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលទាំង ២៥រាជធានីខេត្តមកត្រឹមការតាមដាន និងពិនិត្យយកព័ត៌មានលើប្រព័ន្ធព័ត៌មានសង្គម (ហ្វេសប៊ុកផេក)។ ទោះជាយ៉ាងណាការប្រមូលព័ត៌តាមហ្វេសប៊ុកផេកមានការលំបាកយ៉ាងខ្លាំង ព្រោះថា ហ្វេសប៊ុកផេករបស់អ្នកតំណាងរាស្ត្រដែលរកឃើញ ខ្លះក៏មានព័ត៌មាន ឯខ្លះទៀតរកឃើញហើយតែឈ្មោះដូចគ្នាច្រើនដល់ផែកមើលទៅមិនឃើញមានព័ត៌មានអី ហើយអ្នកតំណាងរាស្ត្រខ្លះទៀត គឺរកមិនឃើញតែម្ដង(ប្រហែលជាអ្នកតំណាងរាស្ត្រមិនប្រើប្រាស់ហ្វេសប៊ុកផេក ឬគណនេយ្យហ្វេសប៊ុក)។

ហេតុនេះ ការប្រមូលព័ត៌មានបេសកកម្មរបស់តំណាងរាស្ត្រចុះមូលដ្ឋានមានដែនកំណត់ ហើយការសរសេររបាយការណ៍ក៏មានដែនកំណត់តាមព័ត៌មានបង្ហាញដែលខុមហ្វ្រែលទទួលបានតាមហ្នឹងដែរ។

# របាយការណ៍ស្តីពី ការសង្ខេបរដ្ឋសភាជាតិ
# ក្នុងឆ្នាំទី២ នីតិកាលទី៦ (២០១៩-២០២០)

ឆ្នាំ២០២០ ជាឆ្នាំទី២ នៃនីតិកាលទី៦ ដែលរដ្ឋសភាបានបន្តនូវបេសកម្មរបស់ខ្លួនក្នុងនាមជានីតិបញ្ញត្តិ ដើម្បីបម្រើផលប្រយោជន៍សម្រាប់ជាតិ ក្នុងនោះមានទាំងកិច្ចការបង្កើត និងកិច្ចការដោះស្រាយ។ កិច្ចការបង្កើត សំដៅដល់ច្បាប់ ដែលរដ្ឋសភាមានកាតព្វកិច្ចពិនិត្យលើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ហើយអនុម័ត ឬវិសោធនកម្មបង្កើតជាច្បាប់សម្រាប់អនុវត្តទូទៅ។ កិច្ចការដោះស្រាយ សំដៅដល់បញ្ហាដែលកើតមានចំពោះជាតិ និងប្រជាពលរដ្ឋ ដែលតំណាងរាស្ត្រត្រូវដោះស្រាយតាមយន្តការបង្កើតច្បាប់ យន្តការចុះអន្តរាគមន៍ យន្តការកោះហៅស្ថាប័នរដ្ឋាភិបាលមកឆ្លើយបំភ្លឺទាក់ទងនឹងផលប្រយោជន៍ជាតិ និងប្រយោជន៍ប្រជាពលរដ្ឋ។

## ១. ដំណើរការសម័យប្រជុំនៃរដ្ឋសភា

ឆ្នាំទី២ នៃនីតិកាលទី៦ គឺរាប់ចាប់ពីខែកញ្ញា ឆ្នាំ២០១៩ ដល់ខែសីហា ឆ្នាំ២០២០។ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានបើកដំណើរការសម័យប្រជុំពេញអង្គរបស់ខ្លួនដែលជាឆ្នាំទី២ នៃនីតិកាលទី៦។ ការបើកសម័យប្រជុំដំបូងនៃឆ្នាំទី២នេះ មានសមាជិកសភាចំនួន ១០៧ រូប បានចូលរួមប្រជុំ ដែលដឹកនាំដោយប្រធានរដ្ឋសភាគឺ សម្តេច ហេង សំរិន ។

### ១.១ ចំនួនកិច្ចប្រជុំរដ្ឋសភាពេញអង្គ

នៅក្នុងឆ្នាំទី២ អាណត្តិទី៦ រដ្ឋសភាបានបើកសម័យប្រជុំពេញអង្គទាំងសាមញ្ញសាធារណៈ និងទាំងវិសាមញ្ញសាធារណៈរបស់ខ្លួនបានចំនួន **៩ដង** ដោយសម្រេចបាននូវរបៀបវារៈចំនួន **៣៩** រួមមាន៖

- ការផ្តល់សច្ចាប័នលើសន្ធិសញ្ញា និងកិច្ចព្រមព្រៀង ចំនួន ១៨
- ច្បាប់ហិរញ្ញវត្ថុ និងថវិកា ចំនួន ៧
- វិសោធនកម្មច្បាប់ ចំនួន ១
- ច្បាប់អនុម័តយល់ព្រមឱ្យកម្ពុជាចូលជាមាជិកស្ថាប័នអន្តរជាតិ និងច្បាប់ផ្សេងៗ ចំនួន ៧
- ច្បាប់បង្កើតស្ថាប័ន ចំនួន ១
- ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត និងកែសម្រួលសមាភាពរាជរដ្ឋាភិបាលចំនួន ៣
- និងចំណុចផ្សេងៗ ទៀត ចំនួន ២

#### ១.១.១ ការអនុម័តយល់ព្រមលើសន្ធិសញ្ញា និងកិច្ចព្រមព្រៀង

ការអនុម័តយល់ព្រមលើសន្ធិសញ្ញា និងកិច្ចព្រមព្រៀងមានចំនួន **១៨** រួមមាន៖

១. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃកិច្ចព្រមព្រៀងក្របខណ្ឌ ស្តីពីការបង្កើតសម្ព័ន្ធភាពថាមពលព្រះអាទិត្យអន្តរជាតិ ដោយសំឡេងយល់ព្រម ១១០ លើ ១១០។

២. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ាន ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយសំឡេងយល់ព្រម ១១០ លើ ១១០។

៣. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី២ ស្តីពីការកំណត់ច្រកទ្វារព្រំដែនឆ្លងកាត់នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីកិច្ចសម្របសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់ ដោយសំឡេងយល់ព្រម ១១០លើ១១០។

៤. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្លំពន្ធ ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល ដោយសំឡេងយល់ព្រម ១០៨ លើ១១០។

៥. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាបំពេញបន្ថែមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយសំឡេងយល់ព្រម ១១០ លើ១១០។

៦. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន សេកុង សឺមម័ល ផៅវ័រ ផ្លេន ខមភេនី លីមីធីត នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដោយសំឡេងយល់ព្រម ១០៨ លើ ១១០។

៧. ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាអោយក្រុមហ៊ុន រ៉ាយសិន អេនើជី (ខេមបូឌា) បាត់ដំបង ឯ.ក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព៦០ មេហ្គាវ៉ាត់ នៅខេត្តបាត់ដំបង ដោយសំឡេងយល់ព្រម ១០៥ លើ ១១០។

៨. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ធីអេសប៊ីភី សេកុង ផៅវ័រ អ៊ែន មីនើរ៉ល ខមភេនី លីមីធីត នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដោយសំឡេងយល់ព្រម ១០៨ លើ១១០។

៩. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេថេក អ៊ីនហ្វីនីត ឯ.ក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតអគ្គិសនី ដើរដោយពន្លឺព្រះអាទិត្យ អានុភាព ៣០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់ ដោយសំឡេងយល់ព្រម ១០៧ លើ ១១០។

១០. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមអោយព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងសម្រាប់អនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រចុះថ្ងៃទី១០ សីហា ឆ្នាំ១៩៨២ ទាក់ទងនឹងការគ្រប់គ្រង និងការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ ដោយសំឡេងយល់ព្រម ១១០ លើ១១០។

១១. ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន វ៉ាយ ផៅវ័រ សឺបផ្លាយ ឯ.ក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព ៣០មេហ្គាវ៉ាត់ នៅខេត្តបន្ទាយមានជ័យ ដោយសំឡេងយល់ព្រម ១០៧ លើ ១១០ ។

១២. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ហ្គ្រីនណឺស្ពែនណឺប៊ល វេនឈ័រ(ខេមបូឌា) ឯ.ក. សម្រាប់គម្រោងសាងសង់ស្ថានីយ៍ផលិតអគ្គិសនី ដើរដោយពន្លឺព្រះអាទិត្យ អានុភាព២០មេហ្គាវ៉ាត់ នៅខេត្តស្វាយរៀង ដោយសំឡេងយល់ព្រម ១០៧ លើ ១១០។

១៣. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយសំឡេងយល់ព្រម ១១៧ លើ ១១៧។

១៤. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិត រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយសំឡេងយល់ព្រម ១១៧ លើ ១១៧។

១៥. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីបី ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន ដោយសំឡេងយល់ព្រម ១១៧ លើ ១១៧។

១៦. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីពីរ ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលាយអាស៊ាន ក្នុងសម្លេងយល់ព្រម ១១៧ លើ ១១៧។

១៧. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធិសារទី១ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីពាណិជ្ជទំនិញអាស៊ាន ដោយសំឡេងយល់ព្រម ១១៧ លើ ១១៧។

១៨.សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាទីក្រុងប៊ែនស្តីពី កិច្ចការពារស្នាដៃអក្សរសាស្ត្រ និងសិល្បៈឆ្នាំ១៨៨៦ និងវិសោធនកម្មឆ្នាំ១៩៧៩ ដោយសំឡេងយល់ព្រម ១១១ លើ ១១១។

**១.១.២ សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើច្បាប់ហិរញ្ញវត្ថុ និងថវិកា**

សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមទូទាត់ថវិកាចំនួន **៧** រួមមាន៖

១. សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដោយសំឡេងយល់ព្រម ១០៨ លើ ១០៨។

២. ការពិភាក្សា និងការអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដោយសំឡេងយល់ព្រម ១០៨ លើ ១០៨។

៣. ការពិភាក្សា និងការអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលឱ្យក្រុមហ៊ុន ហាន សេង ខូល ម៉ាញ សម្រាប់គម្រោងវិនិយោគ សាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនីតង់ស្យុង ២៣០គីឡូវ៉ុល ភ្ជាប់ពីរោងចក្រអគ្គិសនីដុតធ្យូងថ្មខេត្តឧត្តរមានជ័យ មកអនុស្ថានីយសៀមរាបខាងកើត ដោយសំឡេងយល់ព្រម ១០៩ លើ ១០៩។

៤. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ហាន សេង ខូល ម៉ាញ សម្រាប់គម្រោងវិនិយោគ សាងសង់រោងចក្រអគ្គិសនីដុតធ្យូងថ្ម អានុភាព ២៦៥មេហ្គាវ៉ាត់ ខេត្តឧត្តរមានជ័យ ដោយសំឡេងយល់ព្រម ១០៩ លើ ១០៩។

៥. សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប អ៊ិនវេសម៉ិន គ្រុប ឯ.ក សម្រាប់គម្រោងវិនិយោគសាងសង់រោងចក្រអគ្គិសនីដុតធ្យូងថ្ម អានុភាព ៧០០មេហ្គាវ៉ាត់ ខេត្តកោះកុង ដោយសំឡេងយល់ព្រម ១០៩ លើ ១០៩។

៦. សេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដោយសំឡេងយល់ព្រម ១១៩ លើ ១២០ ។

៧. សេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដោយសំឡេងយល់ព្រម ១០៨ លើ១២០។

**១.១.៣ ការពិភាក្សា និងអនុម័ត លើវិសោធនកម្មច្បាប់ មានចំនួន ១៖**

១.សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ មាត្រា ៥៩នៃច្បាប់ស្តីពីសហជីព ដែលត្រូវបានប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលេខ នស/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ដោយសំឡេងយល់ព្រម ១០៧ លើ ១០៨។

**១.១.៤ ការពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់**

ការពិភាក្សា និងអនុម័តនូវសេចក្តីព្រាងច្បាប់មានចំនួន **៧** រួមមាន៖

១. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងអង្គការហាមឃាត់អាវុធគីមី ស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អង្គការហាមឃាត់អាវុធគីមី ដោយសំឡេងយល់ព្រម ១០៥ លើ ១០៨។

២. សេចក្តីព្រាងច្បាប់ស្តីពី សំណង់ ដោយសំឡេងយល់ព្រម ១០៧ លើ ១០៨។

៣. សេចក្តីព្រាងច្បាប់ស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយសំឡេងយល់ព្រម ១០៨ លើ ១០៨។

៤. សេចក្តីព្រាងច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់ ដោយសំឡេងយល់ព្រម ១០៥ លើ ១០៨។

៥. សេចក្តីព្រាងច្បាប់ស្តីពី របបសន្តិសុខសង្គម ដោយសំឡេងយល់ព្រម ១០៨ លើ ១០៨។

៦. សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដោយសំឡេងយល់ព្រម ១១៥ លើ ១១៥

៧. សេចក្តីព្រាងច្បាប់ស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដោយសំឡេងយល់ព្រម ១០៨ លើ ១១០

**១.១.៥ ច្បាប់បង្កើតស្ថាប័ន មានចំនួន១៖**

១.សេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយសំឡេងយល់ព្រម ១១៧ លើ ១១៧។

**១.១.៦ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល មានចំនួន៣៖**

១. ការបោះឆ្នោតជ្រើសតាំង ឯកឧត្តម ឡូយ សុផាត ជាសមាជិកគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក និងឯកឧត្តម ស៊ូ ភិរិន្ទ ជាសមាជិកគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ដោយសំឡេងយល់ព្រម ១១៥ លើ ១១៥ ។

២. ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើការតែងតាំង និងកែសម្រួសមាសភាពរាជរដ្ឋាភិបាល ដោយសំឡេងយល់ព្រម១២០ លើ ១២១។

ក.តែងតាំងទេសរដ្ឋមន្ត្រីៈ

- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ជាទេសរដ្ឋមន្ត្រី
- ឯកឧត្តម ហឹម ឆែម ជាទេសរដ្ឋមន្ត្រី(ទទួលបន្ទុកបេសកកម្មពិសេស)
- ឯកឧត្តម អង្គ វង្សវឌ្ឍានា ជាទេសរដ្ឋមន្ត្រី(ទទួលបន្ទុកបេសកកម្មពិសេស)
- ឯកឧត្តម ត្រាំ អ៊ីវតឹក ជាទេសរដ្ឋមន្ត្រី(ទទួលបន្ទុកបេសកកម្មពិសេស)
- ឯកឧត្តម ពេជ្រ ប៊ុនធិន ជាទេសរដ្ឋមន្ត្រី(ទទួលបន្ទុកបេសកកម្មពិសេស)

ខ.កែសម្រួល និងតែងតាំសមាសភាពរដ្ឋមន្ត្រី

- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ជារដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។
- ឯកឧត្តម កើត រិទ្ធ ជារដ្ឋមន្ត្រីក្រសួង យុត្តិធម៌
- ឯកឧត្តម ជា វ៉ាន់ដេន ជារដ្ឋមន្ត្រីក្រសួង ប្រៃសនីយ៍ និងទូរគមនាគមន៍
- ឯកឧត្តម ឈិត សុខុន ជារដ្ឋមន្ត្រីក្រសួង ធម្មការ និងសាសនា
- ឯកឧត្តម ព្រុំ សុខា ជារដ្ឋមន្ត្រីក្រសួង មុខងារសាធារណៈ

៣. ការបោះឆ្នោតផ្តល់សុពលភាពនៃអាណត្តិរបស់លោកជំទាវ នូ សុវណ្ណនី ជាតំណាងរាស្ត្រមណ្ឌលតាកែវ ជំនួសឯកឧត្តម ជា វ៉ាន់ដេត ដែលសុំលាលេង ដោយសំឡេងយល់ព្រម ១១៥ លើ ១១៥ ។

## ១.១.៧ ការអនុម័ត និងពិភាក្សាលើចំណុចផ្សេងៗទៀត មានចំនួន២ ដូចជា៖

១. របាយការណ៍ស្តីពីសកម្មភាពរបស់រដ្ឋសភា ចន្លោះសម័យប្រជុំរដ្ឋសភាលើកទី២ និងលើកទី៣ នីតិកាលទី៦។

២. ព្រះរាជសារព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជូនសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦។

## ១.២. ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំ

ខុមហ្វ្រែល បានធ្វើការបែងចែកការបញ្ចេញមតិជា ៣ប្រភេទគឺ វិជ្ជមាន អវិជ្ជមាន និងអព្យាក្រឹត លើរបៀបវារៈ ឬតួអង្គ/ស្ថាប័នរដ្ឋាភិបាលណាមួយដែលអ្នកតំណាងរាស្ត្រលើកមកនិយាយ ឬធ្វើការពិភាក្សា។ មតិបែបអព្យាក្រឹត គឺសំដៅដល់មតិធម្មតាទៅលើតួអង្គ ឬស្ថាប័ន ដែលមិនធ្វើការរិះគន់បែបលើក ឬដាក់។ មតិវិជ្ជមាន គឺផ្តោតលើការលើកសរសើរពីគុណសម្បត្តិរបស់សេចក្តីស្នើច្បាប់ សេចក្តីព្រាងច្បាប់ តួអង្គ ឬរបស់ស្ថាប័នណាមួយ ដែលយល់ឃើញពីចំណុចគិតថាប្រសើរ។ រីឯមតិអវិជ្ជមាន គឺសំដៅដល់ការនិយាយពីគុណវិបត្តិរបស់តួអង្គ ឬស្ថាប័នណាមួយ ឬគុណវិបត្តិនៃសេចក្តីស្នើច្បាប់ សេចក្តីព្រាងច្បាប់ ដែលជះឥទ្ធិពល ឬនាំឱ្យមានបញ្ហាប្រឈម។

នៅក្នុងដំណើរការនៃការបើកកិច្ចប្រជុំរបស់រដ្ឋសភាក្នុងឆ្នាំទី២ នៃនីតិកាលទី៦នេះ ខុមហ្វ្រែល សង្កេតឃើញថា ជាមធ្យមភាគមានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំពេញអង្គប្រមាណជា **១១១រូប** ស្មើនឹងប្រមាណជា **៨៨.៨ភាគរយ** នៃចំនួនអ្នកតំណាងរាស្ត្រសរុប១២៥រូប។ ក្នុងសម័យប្រជុំនោះ ឃើញមាន

អ្នកតំណាងរាស្ត្រចំនួន **១៤រូប** ស្មើនឹងប្រមាណជា **១១.២ភាគរយ** នៃចំនួនអ្នកតំណាងរាស្ត្រដែលចូលរួមក្នុងសម័យប្រជុំបានឡើងបញ្ចេញមតិ។[1]

**រូបភាពទី១ សកម្មភាពរបស់តំណាងរាស្ត្រក្នុងសម័យប្រជុំឆ្នាំទី២**



**រូបភាពទី២ ទំនាក់ទំនងតំណាងរាស្ត្រ និងការបញ្ចេញមតិ**




[1] ក្នុងឆ្នាំទី២ នៃអាណត្តិទី៦ រដ្ឋសភាបើកសម័យប្រជុំពេញអង្គសាមញ្ញ និងវិសាមញ្ញជាសាធារណៈបាន៩លើកគឺៈ

១. លើកទី១ សម័យប្រជុំធ្វើនៅថ្ងៃទី ០៤,០៧ និង០៨ ខែ កញ្ញា ឆ្នាំ ២០១៩ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ១០៨រូប
២. លើកទី២ សម័យប្រជុំធ្វើនៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៩ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ១១០រូប
៣. លើកទី៣ សម័យប្រជុំធ្វើនៅថ្ងៃទី ២៦ ខែ វិច្ឆកា ឆ្នាំ ២០១៩ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ១១០រូប
៤. លើកទី៤ សម័យប្រជុំធ្វើនៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៩ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ១១០រូប
៥. លើកទី៥ សម័យប្រជុំវិសាមញ្ញធ្វើនៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០២០ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ១១៧រូប
៦. លើកទី៦ សម័យប្រជុំវិសាមញ្ញធ្វើនៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០២០ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ១០៩រូប
៧. លើកទី៧ សម័យប្រជុំវិសាមញ្ញធ្វើនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ១២១រូប
៨. លើកទី៨ សម័យប្រជុំធ្វើនៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០២០ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ១១៥រូប
៩. លើកទី៩ សម័យប្រជុំធ្វើនៅថ្ងៃទី ០៤-០៥ ខែ មិថុនា ឆ្នាំ២០២០ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ១១២រូប

រូបភាពខាងលើនេះបង្ហាញថា ក្នុងសម័យប្រជុំឆ្នាំទី២ មានអ្នកតំណាងរាស្ត្រ១៤រូប ដែលបានឡើងបញ្ចេញមតិ និងមានចំនួន ៣៨ដង បើគិតជារយៈពេលមានប្រមាណ ២៤១នាទី។

**ក្រាហ្វិកទី១ ការប្រៀបធៀបចំនួននៃការឡើងបញ្ចេញមតិរបស់តំណាងរាស្ត្រ**




នៅក្នុងក្រាហ្វិកខាងលើ បើធ្វើការប្រៀបធៀបឆ្នាំទី២ ដូចគ្នានៃអាណត្តិទី៥ និងអាណត្តិទី៦ ខុមប្រែលសង្កេតឃើញថា ឆ្នាំទី២ នៃអាណត្តិទី៥ មានតំណាងរាស្ត្រ ៤៣រូប (តំណាងរាស្ត្រពីរគណបក្សដែលមានអាសនៈនៅក្នុងសភា) និងរយៈពេលរហូតដល់១១៩៩នាទី ឡើងបញ្ចេញមតិច្រើនជាង៥ដងនៃឆ្នាំទី២ អាណត្តិទី៦។

## ក្រាហ្វិកទី២ ប្រភេទនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រក្នុងសម័យប្រជុំ




តាមការអង្កេតរបស់ខុមហ្វ្រែល ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងការពិភាក្សាលើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ភាគច្រើនបានផ្តោតលើន័យជាវិជ្ជមាន (សរសើរ គាំទ្រគោលនយោបាយរបស់រដ្ឋាភិបាល និងលើកទឹកចិត្តក្នុងការអនុត្តន៍)។ ខ្លឹមសារន័យជាវិជ្ជមាននេះ មានប្រមាណជា ២២២នាទី ស្មើនឹង ៩២.១ភាគរយ នៃចំនួនបញ្ចេញមតិសរុប។ ការបញ្ចេញមតិក្នុងន័យអព្យាក្រឹតគឺប្រមាណ ១៧នាទី ស្មើនឹង ៧.១ភាគរយនៃចំនួនបញ្ចេញមតិសរុប ចំណែកការបញ្ចេញមតិក្នុងន័យបែបអវិជ្ជមានគឺប្រមាណ ២នាទីស្មើនឹង ០.៨ភាគរយនៃចំនួនបញ្ចេញមតិសរុបក្នុងឆ្នាំទី២។

ការបញ្ចេញមតិជាវិជ្ជមានក្នុងសម័យប្រជុំនេះ ខុមហ្វ្រែល បានសង្កេតឃើញមានខ្លឹមសារលើកឡើងក្នុងការបញ្ចេញមតិក្នុងនាមជាតំណាងរាស្ត្រចំពោះសេចក្តីព្រាង ឬស្នើច្បាប់ទាំងនោះ គឺការកោតសរសើរនៃសេចក្តីព្រាងច្បាប់ និងការបង្កើតច្បាប់។ ដូចកាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ រដ្ឋសភា បានធ្វើការពិភាក្សា និងអនុម័តលើ ***សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន***។ ច្បាប់នេះត្រូវបានរដ្ឋសភាគាំទ្រក្នុងសំឡេង ១១៥ លើ ១១៥ នៃសមាជិកសភាចូលរួមប្រជុំ ។ ក្នុងការលើកឡើងពីច្បាប់នេះ ឯកឧត្តម **ឈាង វ៉ុន** តំណាងរាស្ត្រខេត្តបាត់ដំបង មានប្រសាសន៍ថា «ប្រទេសណាក៏គេមានច្បាប់នេះដែរ ហើយយើងតាំងពីសភាធម្មនុញ្ញឆ្នាំ១៩៩៣ មកគឺមិនអាចចេញបានទេច្បាប់នេះ ទើបតែពេលនេះ»។ ឯកឧត្តម **ទី សុគន្ធ** តំណាងរាស្ត្រមណ្ឌលខេត្តកណ្តាល បានមានប្រសាសន៍ក្នុងអង្គប្រជុំថា «អបអរសាទរសម្តេច ហ៊ុន សែន បានផ្តួចផ្តើមសេចក្តីព្រាងច្បាប់ដែលស្របទៅតាមស្ថានភាពនេះ។ ប្រទេសធំៗ

ក្នុងពិភពលោកបានប្រកាន់យកនូវការគ្រប់គ្រងប្រទេសក្នុងស្ថានភាពអាសន្ន»។ មតិជាអវិជ្ជមានវិញ តំណាងរាស្ត្រមិនបានលើកឡើងដោយមតិភាគច្រើននោះទេ ហើយការរិះគន់ពីច្បាប់ដែលបានលើកមកជជែក និងអនុម័តក៏មិនបានបង្ហាញពីភាពខ្វះខាត ឬចន្លោះប្រហោងនៃសេចក្តីព្រាងច្បាប់ដែរ។ កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ ឯកឧត្តម **ប្រាជ្ញ ច័ន្ទ** បានឡើងបញ្ចេញមតិលើច្បាប់ស្តីពី«***ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់***» គឺបានស្នើសុំលុបខ្លឹមសារក្នុងចំណុចខ្លះចោលព្រោះវាជាន់គ្នាជាមួយមាត្រាខាងដើម...។ មតិបែបអព្យាក្រឹត ខុមហ្វ្រែលឃើញមានតំណាងរាស្ត្របញ្ចេញមតិទាក់ទងនឹងបែបអព្យាក្រិតនេះ ដូចជា នៅក្នុងសម័យប្រជុំវិសាមញ្ញសាធារណៈថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២០ លោកជំទាវ **ឡោក ខេង** បានឡើងបញ្ចេញមតិក្នុងរបៀបវារៈទី៣ «***សេចក្តីព្រាងច្បាប់ស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ***»ថា សេចក្តីព្រាងច្បាប់នេះ គឺដើម្បីប្រយុទ្ធប្រឆាំងព្រហ្មទណ្ឌ ជាពិសេសបទឧក្រិដ្ឋឆ្លងដែន អំពើភេរវកម្ម ព្រមទាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មជាដើម...។

**ក្រាហ្វិកទី៣ ការប្រៀបធៀបប្រភេទនៃការបញ្ចេញមតិ**




លទ្ធផលក្នុងតារាងខាងលើបានបង្ហាញថា ឆ្នាំទី២នេះ តំណាងរាស្ត្របានបញ្ចេញមតិចំនួន ២៤១ នាទី ច្រើនជាងឆ្នាំទី១ (២០៩នាទី)។ ការបញ្ចេញមតិក្នុងសម័យប្រជុំសភានេះ អ្វីដែលយើងមើលឃើញគឺន័យជាវិជ្ជមានក្នុងការសរសើរ ឬការលើកតម្កើងពីខ្លឹមសារនៃច្បាប់ដែលតំណាងរាជរដ្ឋាភិបាលបានលើកឡើង មិនខុសពីឆ្នាំទី១ ទេ។

លទ្ធផលនៃការប្រៀបធៀបប្រភេទនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រ បានបង្ហាញថា ឆ្នាំទី២ ដូចគ្នានៃសម័យប្រជុំក្នុងអាណត្តិទី៥ និងទី៦ មានរយៈពេលខុសគ្នា។ ឆ្នាំទី២ នៃអាណត្តិទី៥ មានរយៈ

ពេល ១១៩៩នាទី រីឯអាណត្តិទី៦ មានតែ ២៤១នាទី តិចជាង ៥ដង ហើយនាទីដែលបានបញ្ចេញមតិភាគច្រើនគឺ សំដៅលើន័យអព្យាក្រឹត ផ្ទុយពីអាណត្តិទី៦ ការបញ្ចេញមតិភាគច្រើនគឺន័យជាវិជ្ជមាន។

**ក្រាហ្វិកទី៤ រយៈពេលដែលតំណាងរាស្ត្រនីមួយៗបានបញ្ចេញមតិក្នុងសម័យប្រជុំ**




ក្រាហ្វិកខាងលើ បានបង្ហាញពីអ្នកតំណាងរាស្ត្រទាំង១៤រូប បានឡើងបញ្ចេញមតិ។ តំណាងរាស្ត្រទាំង ១៤រូបនោះមាន ឯកឧត្តម ឈាង វុន បានឡើងធ្វើការបញ្ចេញមតិបានចំនួន ៩ដង ស្មើនឹង ៥៦នាទី និងមានរយៈពេលច្រើនជាងតំណាងរាស្ត្រដទៃទៀត។ ក្នុងចំណោមតំណាងរាស្ត្រដែលបានឡើងបញ្ចេញមតិ។ មានតំណាងរាស្ត្រជាស្ត្រីតែ ១រូបប៉ុណ្ណោះគឺ លោកជំទាវ ឡោក ខេង បានឡើងធ្វើការបញ្ចេញមតិបានចំនួន ៤ដង ស្មើនឹង ៣៣នាទី។

## ១.២ ភាពចម្រូងចម្រាសនៃការបង្កើតច្បាប់

ក្នុងឆ្នាំទី២ នៃអាណត្តិទី៦ រដ្ឋសភាបានប្រជុំដោយលើកយករបៀបវារៈមកពិភាក្សា និងអនុម័តចំនួន **៣៨ របៀបវារៈ**។ ក្នុងចំណោមរបៀបវារៈដែលបានលើកយកមកពិភាក្សានោះ មានរបៀបវារៈចំនួន ២ ដែលមានភាពចម្រូងចម្រាសសម្រាប់ប្រជាជាតិខ្មែរ និងដំណើរការលទ្ធិប្រជាធិបតេយ្យ។ ច្បាប់ទាំង២នោះមានដូចជា៖

1. សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាបំពេញបន្ថែមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។
2. ការអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។

យោងលើរបាយការណ៍នៃព្រះរាជាណាចក្រកម្ពុជា និងប្រទេសវៀតណាម បានបោះបង្គោលព្រំដែនចាប់ពីខេត្តរតនគិរី រហូតដល់ខេត្តកំពត ពីខែមិថុនា ឆ្នាំ២០០៦ ដល់ខែកក្កដា ឆ្នាំ២០១៩ សម្រេចបានលទ្ធផល ៨៤% នៃបង្គោលព្រំដែនធំដែលមានចំនួន ៣៧៥បង្គោល លើដីជាក់ស្តែងដែលបានបោះនៅតាមបណ្តោយខ្សែព្រំដែនរួមរវាងប្រទេសទាំងពីរ ដែលមានប្រវែងប្រមាណជាង១២៧០គីឡូម៉ែត្រ។ បញ្ហាព្រំដែននេះ បានធ្វើឱ្យសកម្មជននយោបាយ អ្នកធ្វើការ ក៏ដូចជាអ្នកខ្វល់ខ្វាយរឿងព្រំដែនមួយចំនួនរងការគំរាមកំហែង ជាប់បទចោទប្រកាន់ពីតុលាការ ហើយមានរហូតដល់ជាប់ធន្ទនាគារក៏មាន ការណ៍នេះបានធ្វើឱ្យមានភាពចម្រូងចម្រាសយ៉ាងខ្លាំង។ មានភាពចម្រូងចម្រាស ក៏ព្រោះតែអ្នកខ្វាយខ្វល់រឿងព្រំដែនយល់ថា សន្ធិសញ្ញានេះបានធ្វើឱ្យកម្ពុជាខាតបង់។ បែបនេះក្តី រដ្ឋសភា ដែលមានគណបក្សតែមួយនៅតែយកសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាបំពេញបន្ថែម លើសន្ធិសញ្ញាកំណត់ព្រំដែនឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម មកអនុម័តដដែល។ សន្ធិសញ្ញានេះ ត្រូវបានរដ្ឋសភាយកមកអនុម័ត កាលពីថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលមានសំឡេងយល់ព្រម ១១០រូបលើសមាសភាពចូលរួម ១១០រូប ។[2]

រីឯការអនុម័តសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ពោរពេញដោយមន្ទិលសង្ស័យពីអ្នកពាក់ព័ន្ធ ដោយសារច្បាប់នេះមិនត្រូវបានរាជរាជរដ្ឋាភិបាលបើកឱ្យមានការជជែកទូលំទូលាយ ឬផ្តល់ឱ្យមានធាតុចូលពីភាគីពាក់ព័ន្ធនោះទេ ជាងនេះទៅទៀត ការតាក់តែងច្បាប់នេះចាប់ពីធ្វើសេចក្តីព្រាងនៅក្នុងដៃរដ្ឋាភិបាលរហូតរុញដល់រដ្ឋសភាដើម្បីធ្វើការអនុម័ត គឺមានរយៈពេលខ្លី។ មានមតិជាច្រើនទាំងថ្នាក់ជាតិ ក៏ដូចជាថ្នាក់អន្តរជាតិថា កម្ពុជាគួរប្រើពេលវេលាសិក្សាឱ្យបានស៊ីជម្រៅជាងនេះ ហើយប្រមូលធាតុចូលពីភាគីពាក់ព័ន្ធឱ្យបានច្រើនមុននឹងបង្កើតច្បាប់នេះ ក្រុមនេះក៏បានរិះគន់លើសេចក្តីព្រាងច្បាប់នេះថា ធ្វើឡើងក្នុងគោលបំណងរិតបន្តឹងសេរីភាពផ្នែកនយោបាយ ដែលបន្ថែមលើស្ថានភាពកំពុងតានតឹងស្រាប់។[3] ទទួលបានការរិះគន់ពីមតិជាតិ និងអន្តរជាតិមែន តែរដ្ឋាភិបាលថា ការបង្កើតច្បាប់នេះឡើង គឺដើម្បីបុព្វហេតុការពារអាយុជីវិតពលរដ្ឋ និងការពារសន្តិសុខជាតិ។[4] បើទោះជាមានមតិខ្វែងគំនិតគ្នាក្នុងការបង្កើតច្បាប់នេះក៏ដោយ ក៏សេចក្តីព្រាងច្បាប់នេះត្រូវបានរដ្ឋសភា លើកយកមកប្រជុំ និងអនុម័តដោយរលូនផងដែរ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ ដែលមាន **៥ជំពូក** និង**១២មាត្រា**

---

2 https://bit.ly/39hoKPw
3 https://www.cambodiadaily.com/2020/04/07/13/44/47962/
4 http://m.freshnewsasia.com/index.php/en/opinioneditorial/153298-2020-04-01-04-54-55.html

ដោយសំឡេងអនុម័តទាំងស្រុង១១៥ លើ ១១៥សំឡេង។ យោងតាមសេចក្តីថ្លែងហេតុរបស់រដ្ឋាភិបាលកម្ពុជា ការបង្កើតច្បាប់នេះឡើង គឺដោយផ្អែកតាមមាត្រា ២២ថ្មី នៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលបានចែងថា «នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា»។ ក៏ប៉ុន្តែ មាត្រា២២ថ្មី ក៏ដូចជាមាត្រាដទៃទៀតនៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣នេះ ពុំបានចែងអំពីវិធានការគ្រប់គ្រងប្រទេសជាតិ ក្រោយពីត្រូវបានប្រកាសដាក់ប្រទេសជាតិឲ្យស្ថិតក្នុងភាពអាសន្នដោយព្រះមហាក្សត្រនោះទេ។[5]

## ២.ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ

តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូលពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ (រដ្ឋធម្មនុញ្ញ មាត្រា៧៧)។ រដ្ឋសភាបានប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ។ សម័យប្រជុំនីមួយៗ មានថេរៈវេលាយ៉ាងតិច ៣ខែ (រដ្ឋធម្មនុញ្ញ មាត្រា៨៣)។ ក្រៅពីតួនាទីជាអ្នកតាក់តែង និងអនុម័តច្បាប់ តំណាងរាស្ត្រក៏មានអំណាចមួយទៀត ដែលមានចែងក្នុងមាត្រា៨៩ មាត្រា៩៦ មាត្រា៩៧ និងមាត្រា៩៨ គឺការផ្តល់អំណាចឱ្យអ្នកតំណាងរាស្ត្រមានសិទ្ធិទម្លាក់រាជរដ្ឋាភិបាល ការដាក់សំណួរទៅរដ្ឋាភិបាល ឬញត្តិស្តីបន្ទោស។ ហេតុដូច្នេះ នៅរាល់ចន្លោះសម័យប្រជុំដែលសភាវិស្សមកាល ជាពេលវេលាមួយផ្តល់ឱ្យតំណាងរាស្ត្រមានលទ្ធភាពចុះមូលដ្ឋាន ដើម្បីសួរសុខទុក្ខ ឬចុះជួយអន្តរាគមន៍លើបញ្ហាផ្សេងៗ ជូនប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត និងទទួលយកនូវអ្វីដែលជាក្តីកង្វល់របស់ម្ចាស់ឆ្នោតមកជជែកក្នុងរដ្ឋសភា។

ទាក់ទងសកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រ អង្គការខុមហ្វ្រែលបានកំណត់រាប់ជាចំនួនដង។ មានន័យថា តំណាងរាស្ត្រចុះទៅទីតាំងមួយកន្លែង ចាត់ទុកថាមួយសកម្មភាព។ ទោះបីជាយ៉ាងណា ខុមហ្វ្រែលនៅមានកម្រិត និងមានភាពខ្វះខាតខ្លះក្នុងការប្រមូលព័ត៌មានទាក់ទងទៅនឹងសកម្មភាពរបស់តំណាងរាស្ត្រផងដែរ ព្រោះថា យើងមិនមានលទ្ធភាពទទួលបានកិច្ចសហការល្អនៅក្នុងការិយាល័យតំណាងរាស្ត្រនៃមណ្ឌលខ្លះ និងមិនមានព័ត៌មានគ្រប់គ្រាន់ពីគ្រប់អ្នកតំណាងរាស្ត្រផងដែរ។

ខុមហ្វ្រែល សូមធ្វើការវិភាគលើទិន្នន័យដាក់ក្នុងរបាយការណ៍ ត្រឹមព័ត៌មានដែលខុមហ្វ្រែលមាន។ សកម្មភាពចុះតាមមូលដ្ឋានជាក់ស្តែងអាចមានចំនួនច្រើនជាងទិន្នន័យដែលខុមហ្វ្រែលប្រមូលបាន។

របាយការណ៍ឆ្នាំទី២ គិតចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០។ ទិន្នន័យដែលខុមហ្វ្រែលបានប្រមូល មាននីតិវិធីដូចជា ការអង្កេត និងប្រមូលព័ត៌មានលើប្រព័ន្ធផ្សព្វផ្សាយ

[5] https://bit.ly/33jws7V

ព័ត៌មានសង្គមហ្វេសប៊ុក និងហ្វេសប៊ុកផេករបស់តំណាងរាស្ត្រផ្ទាល់ ប្រព័ន្ធផ្សព្វផ្សាយរបស់សារព័ត៌មានការិយាល័យតំណាងរាស្ត្រជាដើម។

## ២.១. ចំនួនអ្នកតំណាងរាស្ត្រ និងចំនួននៃការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ

ក្នុងឆ្នាំទី២ នៃអាណត្តិទី៦ តាមរយៈការសង្កេតរបស់ខុមហ្វ្រែលបានបង្ហាញលើក្រាហ្វិកទី៥ ថា ក្នុងចំណោមតំណាងរាស្ត្រចំនួន ១២៥រូប នៃសមាជិករដ្ឋសភាសរុប មានសមាជិកសភា **១០៤រូប** ដែលបានធ្វើសកម្មភាពចុះមូលដ្ឋាន។ សកម្មភាពដែលតំណាងរាស្ត្របានចុះមូលដ្ឋាន មានចំនួនសរុប **៨៩៩លើក**។

**ក្រាហ្វិកទី៥ ចំនួនអ្នកតំណាងរាស្ត្រសរុបបានចុះបេសកកម្មនៅមូលដ្ឋាន**




**ក្រាហ្វិកទី៦ ការប្រៀបធៀបចំនួនបេសកកម្មតំណាងរាស្ត្រតាមឆ្នាំ**



តាមរយៈទិន្នន័យពីការសង្កេតរបស់ខុមហ្វ្រែលបានបង្ហាញថា សកម្មភាពអ្នកតំណាងរាស្ត្រមានចំនួនតិចជាងមុន បើធៀបជាមួយឆ្នាំទី១ តែចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋានមានការកើនឡើង។ កាលឆ្នាំទី១ នៃអាណត្តិទី៦ មានអ្នកតំណាងរាស្ត្រចុះបេសកកម្មចំនួន **៥៥រូប** ចុះបានចំនួន **១០៤១លើក**។ ចំនួនសកម្មភាពនេះ ច្រើនជាងបើធៀបជាមួយឆ្នាំទី២នេះ ដែលមានបេសកកម្មតែ **៨៩៩លើក** (បើគិតជាមធ្យមបានតែ**៩លើក**ប៉ុណ្ណោះ ក្នុងតំណាងរាស្ត្រមួយរូប) ហើយមានតំណាងរាស្ត្ររហូតដល់ **១០៤រូប** បានចុះមូលដ្ឋាន ដែលចំនួនតំណាងរាស្ត្រនេះបើធៀបជាមួយឆ្នាំទី១នៃអាណត្តិជាមួយគ្នា គឺច្រើនជាង។ ទោះជាយ៉ាងណា ក្នុងឆ្នាំទី២ដូចគ្នា ខុមហ្វ្រែល មើលឃើញថា អាណត្តិទី៥ នៅតែមានចំនួនបេសកកម្មច្រើនជាងអាណត្តិទី៦ ដដែល។

## ២.២ គោលបំណងរបស់តំណាងរាស្ត្រចុះមូលដ្ឋាន

ចំពោះគោលបំណងចុះមូលដ្ឋានរបស់តំណាងរាស្ត្រ ខុមហ្វ្រែលបានបែងចែកយកជា ៥គោលបំណង ដើម្បីសង្កេតទៅលើការចុះតាមមូលដ្ឋានរបស់តំណាងរាស្ត្រ។ គោលបំណងសំខាន់ៗ ទាំង ៥នោះ រួមមាន៖ ១.ការសំណេះសំណាល សួរសុខទុក្ខ ចែកអំណោយដល់ប្រជាពលរដ្ឋ ២.ការចុះពង្រឹងផ្ទៃក្នុងរបស់គណៈបក្ស ៣.ការអមដំណើរថ្នាក់ដឹកនាំ ៤.ការចូលរួមវេទិកាសាធារណៈ ៥.ការចុះជួយអន្តរាគមន៍ដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

**ក្រាហ្វិចទី៧ ចំនួន និងភាគរយអ្នកតំណាងរាស្ត្រចុះតាមមូលដ្ឋាន**



តាមក្រាហ្វិចខាងលើបង្ហាញថា ចំនួនភាគរយនៃអ្នកតំណាងរាស្ត្រនៅក្នុងនីតិកាលទី៦ ឆ្នាំទី២នេះ ចុះទៅតាមមូលដ្ឋានភាគច្រើនផ្តោតសំខាន់ទៅលើការសំណេះសំណាល សួរសុខទុក្ខ ចែកអំណោយដល់ប្រជាពលរដ្ឋចំនួន **៧៥៩លើក** ស្មើនឹង**៨៤.៤ភាគរយ**នៃសកកម្មភាពសរុបចំនួន **៨៩៩លើក**។ សកម្មភាពចំនួន **៩៤លើក** ស្មើនឹង **១០.៥ភាគរយ** គឺជាការចុះអមដំណើរថ្នាក់ដឹកនាំ។ សកម្មភាពចំនួន **៣៣លើក** ស្មើនឹង **៣.៧ភាគរយ** គឺជាការចុះពង្រឹងផ្ទៃក្នុងរបស់គណៈបក្ស រីឯការចុះជួយអន្តរាគមន៍ដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋនៅមូលដ្ឋានមានចំនួន **៧លើក**ស្មើនឹង **០.៨ភាគរយ** ចំណែកឯការចូលរួមនៅក្នុងវេទិកាសាធារណៈរបស់តំណាងរាស្ត្រ តាមការសង្កេតរបស់ ខុមហ្វ្រែល ឃើញមានចំនួន **៨លើក** ស្មើនឹង **១ភាគរយ**។

## ២.២.១. ការសំណេះសំណាល

នៅក្នុងឆ្នាំទី២ នីតិកាលទី៦នេះ អ្នកតំណាងរាស្ត្របានចុះតាមមូលដ្ឋានក្នុងគោលបំណងបែបសំណេះសំណាល សួរសុខទុក្ខ និងសម្ពោធសមិទ្ធផលនានាបានចំនួន **៧៥៩លើក** ដែលក្នុងសកម្មភាពនេះមានទាំងសំណេះសំណាលជាមួយប្រជាពលរដ្ឋ មានទាំងសំណេះសំណាលជាមួយអាជ្ញាធរ។ តាមការសង្កេតរបស់ខុមហ្វ្រែលឃើញថា សកម្មភាពតំណាងរាស្ត្រចុះទៅមូលដ្ឋាននេះ ទោះតិចឬច្រើនពួកគាត់តែងផ្សាភ្ជាប់ជាមួយនឹងអំណោយដែលជារបស់ផ្ទាល់ខ្លួន ឬខ្លះទៀតបានមកពីសប្បុរជន ដើម្បីជូនដល់ប្រជាពលរដ្ឋ។ ដោយសារឆ្នាំទី២នៃអាណត្តិទី៦នេះ កម្ពុជាក៏ដូចជាពិភពលោកផងដែរ ដែលទទួលរងនូវជំងឺកូវីដ១៩ ដូច្នេះនៅក្នុងការចុះមូលដ្ឋារបស់តំណាងរាស្ត្រ គឺតែងតែណែនាំប្រជាពលរដ្ឋ និងអាជ្ញាធរឱ្យចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩នេះ បន្តទៀត តាមបទបញ្ជា និងសេចក្តីសម្រេចផ្សេងៗ ស្របតាមការណែនាំរបស់ក្រសួងសុខាភិបាល ដោយត្រូវរស់នៅអនាម័យខ្ជាប់ខ្ជួនលាងដៃនឹងសាប៊ូ ឬអាល់កុល រក្សាគម្លាតឱ្យបានសមស្រប ពាក់ម៉ាស់ ការដាក់ខ្លួនឯងឱ្យនៅដាច់ដោយឡែកពីគេរយៈពេល ១៤ថ្ងៃ បន្ទាប់ពីវិលត្រឡប់ពីក្រៅប្រទេស ជាពិសេសនោះគឺចៀសវាងការប្រមូលផ្តុំគ្នាមានមនុស្សច្រើន។ គ្រប់តំណាងរាស្ត្រដែលចុះមូលដ្ឋានក៏មិនភ្លេចដែរនូវខ្លឹមសារសំណេះសំណាលដែលតែងតែលើកឡើងថាខ្លួនបានពាំនាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខពីថ្នាក់ដឹកនាំរដ្ឋសភា ឬថ្នាក់ដឹកនាំរដ្ឋាភិបាល ជូនប្រជាពលរដ្ឋ ឬអាជ្ញាធរមូលដ្ឋានផងដែរ។ ការចុះសំណេះសំណាលអាជ្ញាធរ ឬប្រជាពលរដ្ឋរបស់តំណាងរាស្ត្រមានដូចជា៖

- តំណាងរាស្ត្រខេត្តកណ្តាល ឯកឧត្តម អ៊ុក ដាមរី និងឯកឧត្តម ឃួន ផល្លារិទ្ធ នាយកខុទ្ទកាល័យលោកជំទាវ កិត្តិសង្គហបណ្ឌិត ឃួន សុដារី អនុប្រធានទី២ នៃរដ្ឋសភាចុះជួបជាមួយអាជ្ញាធរភូមិ

ឃុំ និងគ្រូពេទ្យ ដើម្បីលើកទឹកចិត្ត និងចូលរួមយុទ្ធនាការផ្សព្វផ្សាយស្តីពី វិធីកាត់បន្ថយហានីភ័យនៃការឆ្លងជំងឺកូវីដ១៩។

ដោយពិនិត្យឃើញពីកិច្ចខិតខំប្រឹងប្រែងប្រកបដោយការយកចិត្តទុកដាក់របស់មន្ត្រីរាជការជុំវិញស្រុកលើកដែក ជាពិសេសអាជ្ញាធរភូមិ ឃុំ និងគ្រូពេទ្យ ដែលកំពុងប្រចាំការលើកំណាត់ផ្លូវជាតិលេខ១ ស្ថិតនៅចំណុចព្រំប្រទល់រវាងស្រុកកៀនស្វាយ និងស្រុកលើកដែក។ ការចុះជួបសំណេះសំណាលនេះ បានធ្វើឡើងកាលពីថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០២០។ ដោយក្នុងនោះតំណាងរាស្ត្ររួមទាំងក្រុមការងារ និងសប្បុរសជននានា បានឧបត្ថម្ភថវិកា ស្បៀងឧបភោគបរិភោគ សម្ភារៈ និងបរិក្ខារពេទ្យមួយចំនួន ដល់ក្រុមការងារស្រុក ក្រុមការងារឃុំ កងកម្លាំងប្រជាការពារ និងមណ្ឌលសុខភាពតាមបណ្តាឃុំ ក្នុងស្រុកលើកដែក៕[6]

- **(ត្បូងឃ្មុំ)៖** ឯកឧត្តម ប្រាជ្ញ ចន្ទ តំណាងរាស្ត្រមណ្ឌលត្បូងឃ្មុំ និងជាប្រធានគណៈកម្មការទី១ នៃរដ្ឋសភា នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០នេះ អញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ ដើម្បីស្វែងយល់ និងដោះស្រាយបញ្ហា ជាមួយកងកម្លាំង ក្រុមប្រឹក្សាឃុំ មេភូមិ អនុភូមិ ជំនួយការភូមិ គណៈកម្មការវត្ត នាយកសាលា ប្រធានមណ្ឌលសុខភាព ដែលជាម្ចាស់ឆ្នោតក្នុងឃុំចំនួន៣ គឺឃុំទន្លូង ឃុំត្រមូង ស្រុកមេមត់ និងឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

  នាឱកាសនោះ ឯកឧត្តម ប្រាជ្ញ ចន្ទ បានលើកឡើងអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី បានធ្វើឲ្យប្រទេសជាតិទទួលបាននូវសុខសន្តិភាពស្ថេរភាពពេញលេញ និងការអភិវឌ្ឍជាតិ ការផ្តល់អ្វីៗសព្វបែបយ៉ាងទៅអោយប្រជាពលរដ្ឋ។ ឯកឧត្តម ប្រាជ្ញ ចន្ទ បានផ្តាំផ្ញើដល់ប្រជាពលរដ្ឋទាំងអស់ សូមកុំឲ្យចាញ់បោកជឿឃោសនារបស់ជនអគតិមួយក្រុម គឺជនក្បត់ជាតិដែលតែងតែឃោសនាបំបែកបំបាក់សាមគ្គីភាព ប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ហើយយើងអាចមានទោសទណ្ឌដល់ខ្លួននិងក្រុមគ្រួសារយើងដោយមិនដឹងខ្លួនផងដែរ។[7]

- អ្នកតំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ ឯកឧត្តម ប៉ាល់ សំអឿន លោកជំទាវ នួម សុភ័ណ ឯកឧត្តម អ៊ី ឡុង និងឯកឧត្តម អ៊ុំ រាត្រី អភិបាលនៃគណៈអភិបាលខេត្ត អមដំណើរដោយក្រុមការងារខេត្តចុះជួយស្រុក និងអាជ្ញាធរមូលដ្ឋាន អញ្ជើញចុះជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយជាសម្ភារៈមួយចំនួន ទៅចែកជូនប្រជាពលរដ្ឋចំនួន ៥០គ្រួសារ ដែលមានជីវភាពខ្វះខាត និងចាស់ជរា ក្នុងឃុំតាគង់ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២០។[8]

---

[6] AKP កណ្ដាល ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ https://www.information.gov.kh/articles/17950

[7] ថ្ងៃ ពុធ, 26 កុម្ភៈ, 2020 អត្ថបទដោយ Nou Seyha https://www.cpp.org.kh/details/185681

[8] AKP បន្ទាយមានជ័យ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២០ https://www.information.gov.kh/articles/16227

- ប៉ៃលិន៖ លោកជំទាវបណ្ឌិត បាន ស្រីមុំ តំណាងរាស្ត្រមណ្ឌលប៉ៃលិន និងជាប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជាខេត្តប៉ៃលិន កាលពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ រួមនឹងក្រុមការងារ និងអាជ្ញាធរមូលដ្ឋានភូមិឃុំ បានបន្តចុះសួរសុខទុក្ខ និងផ្តល់អំណោយជាគ្រឿងឧបភោគបរិភោគដល់ប្រជាពលរដ្ឋ ចាស់ជរាមានជីវភាពខ្វះខាតក្នុងភូមិកោះកែវ ឃុំសាលាក្រៅ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ដើម្បីសម្រួលការលំបាកតាមសហគមន៍ដែលរងផលប៉ះពាល់ពីវិបត្តិនៃការរីករាលដាលជំងឺកូវីដ១៩។ ក្នុងឱកាសនោះលោកជំទាវ បាននាំបណ្ដាំផ្ញើសាកសួរសុខទុក្ខពីសំណាក់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ជូនចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងខេត្តប៉ៃលិន ដោយជានិច្ចកាលសម្តេចតែងតែគិតគូរពីសុខទុក្ខ និងជីភាពរស់នៅរបស់ប្រជាពលរដ្ឋទាំងអស់នៅទូទាំងប្រទេស ដោយអំឡុងពេលនេះ រាជរដ្ឋាភិបាល បានយកចិត្តទុក្ខដាក់ខ្ពស់បំផុតចំពោះសុខុមាលភាពប្រជាពលរដ្ឋទូទាំងប្រទេស ដោយបានដាក់ចេញវិធាននានាជាច្រើន ដើម្បីប្រយុទ្ធប្រឆាំង បង្ការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ធ្វើយ៉ាងណាកុំឱ្យជំងឺនេះ មានការរីករាលដាលដល់សហគមន៍។[9]
- នៅព្រឹកថ្ងៃទី៥ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម ងួន បៀន តំណាងរាស្ត្រមណ្ឌលខេត្តកែប និងជាសមាជិកគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី នៃរដ្ឋសភា រួមដំណើរដោយសមាជិកក្រុមប្រឹក្សា ឃុំអង្កោល ជំនួយការ ភូមិអង្កោល និងមន្ត្រីប្រចាំការនៅទីស្នាក់ការរដ្ឋសភាខេត្តកែប បានអញ្ជើញចុះសួរសុខទុក្ខ និងបាននាំយកអំណោយឧបត្ថម្ភដល់ប្រជាពលរដ្ឋរងគ្រោះដោយខ្យល់កន្ត្រាក់ចំនួន ៧គ្រួសារ ស្ថិតក្នុងភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប ដោយក្នុងមួយគ្រួសារទទួលបាន អង្ករ ១៥គីឡូក្រាម ត្រីខកំប៉ុង ៥កំប៉ុង ទឹកស៊ីអ៊ីវ ៣ដប សាប៊ូ ១ដុំ ក្រមា ១ សារុង ១ និងថវិកា ៥០.០០០រៀល។ បន្ទាប់មក ឯកឧត្តម និងក្រុមការងារបានអញ្ជើញចូលរួមឧបត្ថម្ភដល់គ្រួសារសពនៅភូមិភ្នំលាវ ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប ផងដែរ ។[10]
- ខេត្តស្ទឹងត្រែង៖ ឯកឧត្តម ឡូយ សុផាត អ្នកតំណាងរាស្ត្រមណ្ឌលស្ទឹងត្រែង បានដឹកនាំមន្ត្រីក្រោមឱវាទ អមដំណើរដោយអភិបាលរងខេត្ត តំណាងឯកឧត្តមអភិបាលខេត្តស្ទឹងត្រែង មន្ត្រីបច្ចេកទេស និងគណៈអភិបាលស្រុក ថាឡាបរិវ៉ាត់ បានអញ្ជើញចុះសួរសុខទុក្ខប្រជាពលរដ្ឋ និងបានត្រួតពិនិត្យអំពីវឌ្ឍនៈភាព នៃការសាងសង់ផ្លូវក្រាលគ្រួសក្រហមឆ្លងកាត់ឃុំចំនួន៤ ដែលស្ថិតនៅក្នុង ស្រុកថាឡាបរិវ៉ាត់ និងស្រុកសៀមបូក ក្នុងដែនដីរដ្ឋបាលខេត្តស្ទឹងត្រែង ។ មានប្រសាសន៍ទៅកាន់ប្រជាពលរដ្ឋ ឯកឧត្តម ឡូយ សុផាត បានលើកឡើងនូវប្រសាសន៍ផ្តាំផ្ញើ និងសួរសុខទុក្ខពីសំណាក់ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុនសែន ដោយសម្តេចទាំងទ្វេរតែងតែយកចិត្តទុកដាក់ពីសុខទុក្ខរបស់បងប្អូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាននានា ហើយជាពិសេសនោះ គឺនៅតំបន់ដាច់ស្រយ៉ាលដែលជួបការលំបាក និងងាយ

[9] ថ្ងៃ ច័ន្ទ ទី ១៣ ខែ មេសា ឆ្នាំ ២០២០ http://www.apsaracentral.com/article/24686
[10] PEN AKAKMONYAUGUST 5, 2020 4-ព័ត៌មាន-NEWS https://www.ggi.law/18990

រងគ្រោះ ។ ឯកឧត្តម បានបន្ថែមថា ដោយមើលឃើញពីទុក្ខលំបាករបស់បងប្អូនប្រជាពលរដ្ឋយើង អំពីការខ្វះខាតផ្លូវសម្រាប់ធ្វើដំណើរ និងដឹកជញ្ជូនកសិផលទៅកាន់ទីប្រជុំជន ដោយពីមុនធ្វើដំណើរមានការលំបាក តាមព្រៃចាស់ ឆ្លងអូរ តាមម៉ូតូ ឬគោយន្ត និងប្រើរយៈពេលយូរផងដែរ តែពេលនេះមានផ្លូវគ្រួសក្រហមសម្រាប់ធ្វើដំណើរ និង ជួយសម្រួលបានមួយកម្រិត ជួយកាត់បន្ថយពេលវេលា និងថវិកាជាដើម ។ ទន្ទឹមនឹងនោះ ឯកឧត្តម បានសំណូមពរដល់ប្រជាពលរដ្ឋដែលរស់នៅតំបន់នេះសូមធ្វើយ៉ាង ត្រូវថេះថែរក្សាផ្លូវនេះឲ្យបានគង់វង្ស តដល់កូនចៅជំនាន់ក្រោយ បានប្រើប្រាស់ក្នុងការធ្វើដំណើរប្រកបដោយភាពងាយស្រួល។[11]

## ២.២.២.ការចុះពង្រឹងផ្ទៃក្នុងរបស់គណៈបក្ស

នៅក្នុងឆ្នាំទី២ នីតិកាលទី៦នេះ ក៏មិនខុសពីឆ្នាំទី១ដែរ ខុមប្រែ្យលបានសង្កេតឃើញថាសកម្មភាពដែលអ្នកតំណាងរាស្ត្របានចុះតាមមូលដ្ឋានក្នុងគោលបំណងចុះពង្រឹងផ្ទៃក្នុងរបស់បក្ស មាន**ចំនួន ៣៣លើក**។ ខ្លឹមសារនៃការចុះពង្រឹងផ្ទៃក្នុងគណបក្សនេះមានករណីដូចខាងក្រោម៖

- នៅព្រឹកថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ ២០២០ ឯកឧត្តម នាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន អ្នកតំណាងរាស្ត្រមណ្ឌលខេត្តបន្ទាយមានជ័យ និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តបន្ទាយមានជ័យ បានអញ្ជើញជាអធិបតីក្នុងពិធីប្រជុំផ្សព្វផ្សាយ ស្មារតីសន្និបាតគណៈកម្មាធិការកណ្តាល លើកទី៤២ អាណត្តិទី៥ នៅមន្ទីរគណបក្សខេត្ត។[12]
- កិច្ចប្រជុំបូកសរុបការងារគណបក្ស និងក្រុមការងារចុះជួយខេត្តកំពង់ចាមប្រចាំឆ្នាំ២០១៩ និងលើកទិសដៅភារកិច្ចឆ្នាំ២០២០ ព្រមទាំងផ្សព្វផ្សាយខ្លឹមសារនៃសន្និបាតគណៈកម្មាធិការកណ្តាលលើកទី៤២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី ប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកំពង់ចាម នៅថ្ងៃអាទិត្យ ១ រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២០។[13]
- នៅរសៀលថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០២០ ឯកឧត្តម ប៊ូ ឡាំ សមាជិកគណៈកម្មាធិការកណ្តាល និងជាអ្នកតំណាងរាស្ត្រមណ្ឌលរតនគិរី បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពី ជីវភាពការងារគណបក្សរបស់ក្រុមការងារគណបក្សចុះមូលដ្ឋានខេត្តរតនគិរី កិច្ចប្រជុំនេះបានប្រារព្ធឡើងនៅសាលមហោស្រពសម្តេចតេជោហ៊ុន សែន។[14]

---

[11] ដោយ៖ម៉ា ដេង ថ្ងៃ អង្គារ ទី ២១ ខែ មករា ឆ្នាំ ២០២០ http://apsaracentral.com/article/21813

[12] ហ្វេសប៊ុកផេក ខុទ្ទកាល័យឯកឧត្តម នាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន https://www.facebook.com/permalink.php?story_fbid=2881592571902890&id=1115449705183861

[13] ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី-Yim ChhayLy https://www.facebook.com/yimchhaylydeputyprimeminister/posts/2672527766163730

[14] https://www.facebook.com/boulamlawmaker/posts/652251922022635

### ២.២.៣. អមដំណើរថ្នាក់ដឹកនាំ

នៅក្នុងឆ្នាំទី២ នីតិកាលទី៦នេះ ខុមហ្វ្រែលបានសង្កេតឃើញថា សកម្មភាពដែលអ្នកតំណាងរាស្ត្រ បានចុះតាមមូលដ្ឋានក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំមានចំនួន **៩៤លើក**។ ខ្លឹមសារនៃការចុះអម ដំណើរថ្នាក់ដឹកនាំនេះ ។

- ពោធិ៍សាត់៖ ព្រឹកថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២០ ឯកឧត្តម ខូយ សុខា អ្នកតំណាងរាស្ត្រខេត្ត ពោធិ៍សាត់ បានចូលរួមដំណើរជាមួយឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ព្រម ទាំងក្រុមការងារថ្នាក់ជាតិចុះជួយខេត្តពោធិ៍សាត់ ចុះសិក្សាគម្រោងជីកស្រះទឹកជូនប្រជាពលរដ្ឋ ក្នុងទីតាំងមួយចំនួនដូចជា៖ ស្រះទឹកទី១ ស្ថិតនៅក្នុងភូមិឆ្នោះតាចាប ឃុំស្នាមព្រះ ដែលមានទំហំ ស្មើរហ្នឹង ៥០ម៉ែត្រ គុណនឹង ៣៣៣ម៉ែត្រ ជម្រៅ ៥ម៉ែត្រ។ ស្រះទឹកទី២ ឋិតនៅក្នុងភូមិតាម៉ុ ឃុំមេ ទឹក មានទំហំស្មើនឹង ៨៧ គុណនឹង ១៤០ម៉ែត្រជាង ជម្រៅ ១០ម៉ែត្រ ការជីកស្រះនេះ ឯឧត្តមរដ្ឋ មន្ត្រី លោកមានគោលបំណងចង់ផ្គត់ផ្គង់ទឹកអោយបានគ្រប់គ្រាន់តាមសំណូមពររបស់ប្រជា កសិករ ដើម្បីដាំដំណាំធម្មជាតិបានខួបប្រាំង ខួបវស្សាតាមតម្រូវការ។[15]
- នៅព្រឹកថ្ងៃអង្គារ ៣រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០២០នេះ លោកជំទាវ ម៉ាណ ណាវី សមាជិករដ្ឋសភាជាតិ អញ្ជើញចូលរួមអមដំណើរសម្តេចអគ្គ មហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោក ផាក ហ៊ឹង យ្យុង (Park Heung-Kyeong) ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េ ប្រចាំនៅកម្ពុជា បានអញ្ជើញជា អធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកការដ្ឋានស្ពារ និងសាងសង់ផ្លូវលេខ២ និងលេខ២២ ប្រវែងសរុបជាង ៧២គីឡូម៉ែត្រ។[16]

### ២.២.៤. ការចុះជួយអន្តរាគមន៍

នៅក្នុងឆ្នាំទី២ នីតិកាលទី៦នេះ ខុមហ្វ្រែល សង្កេតឃើញថាសកម្មភាពដែលអ្នកតំណាងរាស្ត្របាន ចុះតាមមូលដ្ឋានក្នុងគោលបំណងចុះជួយអន្តរាគមន៍មានចំនួន **៧ដង**។ ក្នុងនោះមានដូចជា៖

- កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ ឯកឧត្តម ប៊ូ ឡាំ អ្នកតំណាងរាស្ត្រមណ្ឌលរតនគិរី បានជួបជាមួយតំណាងប្រជាពលរដ្ឋមកពីឃុំចំនួន២ គឺឃុំសេដា និងឃុំកាឡែង ស្រុកលំ ផាត់ ខេត្តរតនគិរី ដឹកនាំដោយលោកមេឃុំទាំង២ នៅការិយាល័យតំណាងរាស្ត្រមណ្ឌល ខេត្តរតនគិរី ដែលមកសុំការអន្តរាគមន៍ពាក់ព័ន្ធបញ្ហាដីធ្លី ដែលមន្ត្រីឧទ្យានុរក្ស នៃមន្ទីរប រិស្ថានខេត្ត បានហាមឃាត់ប្រជាពលរដ្ឋក្នុងឃុំទាំង២ មិនឲ្យបង្កបង្កើនផលលើដីកសិកម្ម ដែលមានតាំងពីដូនតារបស់ពួកគាត់មកម្ល៉េះ។

---

[15] ហ្វេសប៊ុកផេក ឯកឧត្តម ខូយ សុខា

https://www.facebook.com/permalink.php?story_fbid=690145221767892&id=319565588825859

[16] ហ្វេសប៊ុកផេក Man Navy Member Of Parliament

https://www.facebook.com/permalink.php?story_fbid=193367835365979&id=102149901154440

ឯកឧត្តម ប៊ូ ឡាំ បានសន្យាថា ឯកឧត្តម នឹងពិនិត្យសិក្សានូវអ្វីដែលតំណាងប្រជាពលរដ្ឋបានលើកឡើងនាពេលនេះ ហើយសរសេរជារបាយការណ៍ជូនទៅអាជ្ញាធរខេត្ត ដើម្បីពិនិត្យដោះស្រាយតាមការជាក់ស្តែងពីព្រោះតំណាងរាស្ត្រមិនអាចលូកដៃចូលកិច្ចការងារខាងនីតិប្រតិបត្តិបានទេ គឺបានត្រឹមតែបញ្ជូនរាល់សំណូមពរ និងក្តីកង្វល់របស់ប្រជាពលរដ្ឋទៅខាងនីតិប្រតិបត្តិដោះស្រាយតាមឋានានុក្រម។[17]

## ២.៣ មណ្ឌលរាជធានី ខេត្ត ដែលតំណាងរាស្ត្របានចុះបេសកកម្ម

តំណាងរាស្ត្ររដ្ឋសភា ជាតំណាងរាស្ត្រប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ(រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៧៧)។ មាត្រានេះបានសង្កត់ធ្ងន់ឱ្យតំណាងរាស្ត្រត្រូវតែទទួលខុសត្រូវលើបញ្ហាប្រជាជាតិទាំងមូល មិនមែនឱ្យទទួលត្រឹមមណ្ឌលដែលខ្លួនឈរឈ្មោះ ហើយជាប់ឆ្នោតប៉ុណ្ណោះនោះទេ។ ជាក់ស្តែងការចុះបេសកកម្មរបស់តំណាងរាស្ត្រ ខ្លះមាននៅក្នុងមណ្ឌលរបស់ខ្លួន ហើយមានខ្លះទៀតបានចុះទៅក្រៅមណ្ឌល។

តំណាងរាស្ត្រក្នុងឆ្នាំទី២ មានចំនួន ១០៤រូប បានចុះបេសកកម្មទៅមូលដ្ឋានសរុបមានចំនួន **៨៩៩លើក** ក្នុងនោះតំណាងរាស្ត្រដែលបានចុះមូលដ្ឋាននៅក្នុងមណ្ឌលរបស់ខ្លួនមានចំនួន **៦៨១លើក**។ ចំណែកការចុះមូលដ្ឋានក្រៅមណ្ឌលរបស់អ្នកតំណាងរាស្ត្រមានចំនួន **២១៨លើក**។

**ក្រាហ្វិចទី៨ ចំនួនបេសកកម្មតាមមណ្ឌល**




[17] ភួង ផុន_សារព័ត៌មាន VD7 News, ថ្ងៃទី២៧ មេសា ២០២០ " លោកមេឃុំចំនួន២ឃុំ តំណាងឱ្យពលរដ្ឋក្នុងឃុំ សុំតំណាងរាស្ត្រជួយអន្តរាគមន៍ ករណីមន្ត្រីបរិស្ថានមិនឲ្យប្រជាពលរដ្ឋអាស្រ័យផលលើដីស្រែចំការរបស់ពួកគាត់" http://www.vd7news.com/?p=10909

តាមការបង្ហាញរបស់ក្រាហ្វិចខាងលើ មណ្ឌលដែលមាន សកម្មភាពអ្នកតំណាងរាស្ត្រចុះមូលដ្ឋានច្រើនជាងគេគឺ មណ្ឌលរាជធានីភ្នំពេញ និងខេត្តកំពង់ចាម ។

## ៣. គណៈកម្មការជំនាញនៃរដ្ឋសភា

គណៈកម្មការជំនាញ គឺជាគណៈកម្មការដែលទទួលបន្ទុកបច្ចេកទេសរបស់រដ្ឋសភា ជាសេនាធិការរបស់រដ្ឋសភាក្នុងការសម្របសម្រួលនៅក្នុងរដ្ឋសភា និងក្រៅរដ្ឋសភា (ជាមួយដៃគូរពាក់ព័ន្ធជាតិ និងកិច្ចការការទូត)ជាដើម។ គណៈកម្មការជំនាញមានតួនាទីសិក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលបានបញ្ជូនមកពីគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា តាមមុខជំនាញរបស់ខ្លួន ហើយមានបេសកកម្មចុះមូលដ្ឋានដែលត្រូវបានចែកដាច់ដោយឡែកពីសកម្មភាពរបស់តំណាងរាស្ត្រ។

គណៈកម្មការជំនាញមានភារកិច្ចទទួលបន្ទុកត្រួតពិនិត្យលើស្ថាប័ន ឬក្រសួង ដែលពាក់ព័ន្ធនឹងដែនសមត្ថកិច្ចរបស់គណៈកម្មការ ជាពិសេសគឺការចុះទៅមូលដ្ឋានដើម្បីសិក្សាស្វែងយល់នូវបញ្ហាប្រជាពលរដ្ឋជួយអន្តរាគមន៍នៅពេលប្រជាពលរដ្ឋជួបប្រទះបញ្ហារំលោភបំពាន និងភាពអយុត្តិធម៌នានា ដែលកើតចេញពីអាជ្ញាធរមិនបានបំពេញតួនាទីអោយបានត្រឹមត្រូវទៅតាមច្បាប់ និងកោះហៅសមាជិករដ្ឋាភិបាលមកឆ្លើយបំភ្លឺជាដើម។

គណៈកម្មការនីមួយៗមានតួនាទី និងបេសកកម្មចម្បងដែលត្រូវទទួលខុសត្រូវចំនួន២សំខាន់ៗគឺ ១.សិក្សាស្រាវជ្រាវប្រមូលធាតុចេញធាតុចូលពីភាគីពាក់ព័ន្ធ ដើម្បីបង្កើតច្បាប់ដែលរដ្ឋាភិបាល សមីក្រសួងបានព្រាង ឬសមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា ស្នើឡើង និង ២.ការចុះបេសកកម្មទៅមូលដ្ឋាន។

### ៣.១ ការសិក្សាស្រាវជ្រាវប្រមូលធាតុចេញធាតុចូលនៃច្បាប់

ក្រោយពីគណៈកម្មការអចិន្ត្រៃយ៍បញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់មកដល់ដៃខ្លួនហើយ គណៈកម្មការជំនាញ ត្រូវរៀបចំដំណើរការដូចខាងក្រោម៖

- ប្រជុំត្រឹមផ្ទៃក្នុងគណៈកម្មការជំនាញ ឬ
- រៀបចំវេទិកាសាធារណៈ ( ស្តាប់ និងប្រមូលអនុសាសន៍ពីសាធារណៈមតិ ) ។
- ឬ ប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ឬតំណាងក្រុមតំណាងរាស្ត្រ ឬក្រុមសមាជិកព្រឹទ្ធសភាហត្ថលេខីនៃសេចក្តីស្នើច្បាប់ ( ប្រជុំមួយលើក ឬច្រើនលើក កែប្រែ ឬរក្សាទុកទាំងស្រុង ) រួចអនុម័ត ព្រម ឬមិនព្រមដាក់ចូលសម័យប្រជុំរដ្ឋសភា ។

លទ្ធផលទទួលបានពីការប្រជុំ ឬវេទិកាសាធារណៈយ៉ាងណានោះ គណៈកម្មការជំនាញត្រូវធ្វើលិខិតជូនប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ធ្វើរបាយការណ៍ អំពីលទ្ធផលនៃការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ។[18]

## ៣.២ បេសកកម្មនៃការចុះមូលដ្ឋានរបស់គណៈកម្មការជំនាញ

បេសកកម្មរបស់គណៈកម្មការជំនាញទៅមូលដ្ឋាននេះគឺ ដើម្បីត្រួតពិនិត្យលើការអនុវត្តិការងាររបស់ក្រសួង ឬស្ថាប័ន ក្នុងសមត្ថកិច្ចរបស់ខ្លួន ចុះសិក្សាបញ្ហា និងរកដំណោះស្រាយជូនប្រជាពលរដ្ឋ និង ការកោះហៅមន្ត្រីមកឆ្លើយបំភ្លឺជាដើម។

នៅក្នុងឆ្នាំទី២នេះ ខុមប្រែ្ហលសង្កេតឃើញថា គណៈកម្មការជំនាញទាំង១០ នៃរដ្ឋសភាមានតែគណៈកម្មការជំនាញតែ៨ប៉ុណ្ណោះដែលបានធ្វើសកម្មភាពចុះមូលដ្ឋានសរុបចំនួន **៥៥លើក**។[19]

**ក្រាហ្វិកទី៩ សកម្មភាពរបស់គណៈកម្មការជំនាញ**




តាមរយៈក្រាហ្វិកខាងលើបានបង្ហាញថា៖ គណៈកម្មការទី១ ចុះបាន**៦លើក** គណៈកម្មការទី២ ចុះបាន **៤លើក** គណៈកម្មការទី៣ ចុះបាន **១៣លើក** គណៈកម្មការទី៦ ចុះបាន **២លើក** គណៈកម្មការទី៧ ចុះ

[18] នីតិវិធីពិនិត្យ និង អនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ នៅក្នុងចំនុចទី២ ខ. http://national-assembly.org.kh/group-article/38

[19] រាល់ព័ត៌អំពីសកម្មភាពរបស់គណៈកម្មការជំនាញទាំង១០នៃរដ្ឋសភា ត្រូវបានប្រមូលតាមគេហទំព័រផ្លូវការរបស់រដ្ឋសភាជាតិ។ ចំពោះសកម្មភាពដែលពាក់ព័ន្ធនឹង បេសកម្មនៅក្រៅប្រទេស, ការប្រជុំពិភាក្សានៅក្នុងក្រុមការងាររបស់ខ្លួន និងការចូលជួបជាមួយគណៈប្រតិភូបរទេស មិនត្រូវបានរាប់បញ្ចូលឡើយ។

បាន **៦លើក** គណៈកម្មការទី៨ ចុះបាន **១៣លើក** គណៈកម្មការទី៩ ចុះបាន **៨លើក** និងគណៈកម្មការទី ១០ ចុះបាន **១លើក**។ ក្នុងចំណោមគណៈកម្មការដែលបានធ្វើបេសកកម្មទៅមូលដ្ឋាន មានតែគណៈកម្មការ២ប៉ុណ្ណោះ ដែលមានបេសកកម្មលើសពី១០(ដប់)លើក គឺគណៈកម្មការទី៣ និង គណៈកម្មការទី៨។ ចំណែកគណៈកម្មការជំនាញទី៤ និងទី៥ ខុមហ្វ្រែលពុំឃើញមានសកម្មភាពចុះមូលដ្ឋាននោះទេ។[20] ក្នុងចំណោម៥៥លើកនោះ គោលបំណងរចុះសួរសុខទុក្ខ ចែកអំណោយ ធ្វើការផ្សព្វផ្សាយ និងធ្វើការសិក្សាស្វែងយល់អំពីតួនាទីនៅតាមមូលដ្ឋានច្រើនជាងគេ គឺបានចំនួន**៥១លើក** ការចុះពង្រឹងបណ្តាញបក្សបានចំនួន**១លើក** ចូលរួមក្នុងវេទិកា ឬកិច្ចប្រជុំបានចំនួន**២លើក** និងចុះអមដំណើរថ្នាក់ដឹកនាំបានចំនួន**១លើក**។ ចំណែកសកម្មភាពរបស់គណៈកម្មការជំនាញដែលពាក់ព័ន្ធនឹងការចុះអន្តរាគមន៍ និងការកោះហៅសមាជិករដ្ឋាភិបាលមកឆ្លើយបំភ្លឺ ខុមហ្វ្រែលសង្កេតឃើញថា មិនដែលឃើញគណៈកម្មការជំនាញណាមួយ ធ្វើកិច្ចការនេះឡើយ។ បើទោះបីជារដ្ឋធម្មនុញ្ញបានប្រគល់អំណាចទៅអោយស្ថាប័នរដ្ឋសភាយ៉ាងណាក៏ដោយ ក៏ស្ថាប័នមួយនេះមិនបានប្រើអំណាចរបស់ខ្លួនអោយមានប្រសិទ្ធិភាពនៅក្នុងតួនាទីភាពជាតំណាងរបស់ប្រជាពលរដ្ឋឱ្យបានពេញលេញដែរ ជាពិសេសពាក់ព័ន្ធនឹងអន្តរាគមន៍នេះតែម្តង។ កម្ពុជាមានបញ្ហាជាក់ស្តែងជាច្រើនដែលកើតឡើងដូចជា បញ្ហាព្រំដែនជាតិ បញ្ហាប្រឈមរបស់ប្រជាពលរដ្ឋក្នុងរឿងដីធ្លី បញ្ហាព្រៃឈើ ឬវិស័យយុត្តិធម៌ជាដើម។

### ៣.២.១ ការកោះហៅសមាជិករដ្ឋាភិបាល ឬមន្ត្រីតំណាងក្រសួងមកឆ្លើយបំភ្លឺ

នៅក្នុងឆ្នាំទី២ នៃអាណត្តិទី៦នេះ ខុមហ្វ្រែលសង្កេតឃើញថា មិនមានគណៈកម្មការណាមួយបានកោះហៅ សមាជិករដ្ឋាភិបាល ឬរដ្ឋមន្ត្រីនៃក្រសួងណាមួយមកបំភ្លឺករណីផ្សេងៗដែលបានកើតឡើងនោះទេ ដូចជាករណី៖

- **បញ្ហាព្រំដែន៖** ករណីវៀតណាមបោះតង់នៅតាមព្រំដែនកម្ពុជា វៀតណាម ហើយករណីនេះ វៀតណាមបានប្រែក្លាយពីតង់ធម្មតាទៅជាសំណង់រឹងមាំទៀតផង។[21] នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៩៦ វាក្យខណ្ឌទី១ និងទី២ ចែងថា *តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល។ សំណួរនេះត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា។ ចម្លើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូប ឬច្រើនរូប អាស្រ័យដោយបញ្ហាដែលបានចោទឡើងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់មន្ត្រីមួយរូប ឬច្រើនរូប។ បើបញ្ហាពាក់ព័ន្ធដល់*

[20] គណៈកម្មការទី៤ គឺ គណៈកម្មការ មហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ និងគណៈកម្មការទី៥ គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន មិនឃើញមានសកម្មភាពនៅក្នុងឆ្នាំទី១ឡើយ។

[21] ហ៊ុល រស្មី សារព័ត៌មាន វីអូអេ, ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០, "អាជ្ញាធរខេត្តកណ្តាលថា យោធាវៀតណាមសង់ជម្រករឹងមាំថ្មីនៅព្រំដែន" https://khmer.voanews.com/a/kandal-provincial-police-reports-vietnamese-military-building-new-firm-shelter-on-border/5560193.html

*នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន។* មាត្រា ៩៧ *គណៈកម្មការទាំងឡាយរបស់រដ្ឋសភា អាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន។* បើទោះជាមានចែងបែបនេះក្តី ក៏ក្នុងស្ថានភាពបែបនេះ គឺមិនឃើញមានគណៈកម្មការជំនាញពាក់ព័ន្ធណាមួយចុះស៊ើបអង្កេត ឬហៅតំណាងរដ្ឋាភិបាលមកសួរនាំឆ្លើយបំភ្លឺរឿងព្រំដែននេះដែរ។

- **បញ្ហាដីធ្លី៖** ជំនួញអចលនទ្រព្យមានការកើនឡើង និងមានតម្លៃខ្លាំង ធ្វើឱ្យបញ្ហានេះកាន់តែធ្ងន់ធ្ងររវាងមន្ត្រីអ្នកមានអំណាចបុណ្យសក្តិ អ្នកមានទ្រព្យធន អាជ្ញាធរមានសមត្ថកិច្ច ជាមួយពលរដ្ឋ បង្កើតបានជារូបភាពធ្វើទុក្ខបុកម្នេញពីសំណាក់មន្ត្រី អាជ្ញាធរទៅលើប្រជាពលរដ្ឋ និងបង្កជាភាពកើតទុក្ខមិនសុខចិត្តរបស់ប្រជាពលរដ្ឋ ហើយនាំគ្នាលើកបដាតវ៉ា ដើម្បីសុំភាពយុត្តិធម៌ និងដំណោះស្រាយសមស្រប ក៏មិនឃើញមានគណៈកម្មការណាកោះហៅមន្ត្រីអ្នកអនុវត្តច្បាប់មកឆ្លើយបំភ្លឺដែរ។

### ៣.២.២ កិច្ចអន្តរាគមន៍របស់គណៈកម្មការជំនាញ

តួនាទី ភារកិច្ចរបស់គណៈកម្មការជំនាញនៅពេលប្រជាពលរដ្ឋមានវិវាទជាមួយអាជ្ញាធរក្នុងផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនៅសហគមន៍ ហើយពុំមានដំណោះស្រាយសមស្របណាមួយដែលពលរដ្ឋអាចទទួលយកបាន ឬក៏មានការធ្វើទុក្ខទារុណណាមួយពីអាជ្ញាធរទៅលើប្រជាពលរដ្ឋ គណៈកម្មការមានភារកិច្ចចុះពិនិត្យ និងតាមដានដោយចិត្តទុកដាក់ (ព្រោះគណៈកម្មការជំនាញរបស់រដ្ឋសភាជាអ្នកត្រួតពិនិត្យលើការអនុវត្តិច្បាប់របស់មន្ត្រី អាជ្ញាធរមានសមត្ថកិច្ច) ក្នុងករណីដែលពិនិត្យទៅឃើញមានភាពមិនប្រក្រតីដែលធ្វើឱ្យប៉ះពាល់ផលប្រយោជន៍រួម និងប្រយោជន៍ប្រជាពលរដ្ឋនោះ គណៈកម្មការមានសិទ្ធិ និងកាតព្វកិច្ចអន្តរាគមន៍ដើម្បីដោះស្រាយនូវបញ្ហាទាំងនោះ។

ទោះជាយ៉ាងណា នៅក្នុងឆ្នាំទី២នេះ ខុមហ្វ្រែលសង្កេតឃើញថា មិនមានគណៈកម្មការណាមួយបានចុះអន្តរាមគមន៍ដើម្បីជួយប្រជាពលរដ្ឋនោះទេ។ ការមិនអន្តរាគមន៍នេះហើយ ដែលជាហេតុធ្វើឱ្យមន្ត្រី អាជ្ញាធរ និងអ្នកមានធនធាន កាន់តែអនុវត្តឃ្លាតចាកពីច្បាប់ និងឃ្លាតចាក់ពីសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ហើយក៏បង្កទៅជាវិវាទរវាងអ្នកមានទ្រព្យសម្បត្តិជាមួយពលរដ្ឋ រវាងមន្ត្រីជាមួយពលរដ្ឋ រវាងអ្នកមានខ្នងមានអំណាចជាមួយប្រជាពលរដ្ឋ។ បញ្ហាកើតមានឡើងធ្ងន់ធ្ងរតែមិនមានដំណោះស្រាយសមស្រប ឬកិច្ចអន្តរាគមន៍ពីគណៈកម្មការជំនាញ មានដូចជា៖

- **បញ្ហាដីធ្លី** និន្នាការនៃការអភិវឌ្ឍនៅកម្ពុជាបានរីករាលដាលនៃវិវាទដីធ្លី និងការរំលោភបំពានសិទ្ធិកាន់កាប់ដី។ សម្បទានដីសេដ្ឋកិច្ច ត្រូវបានរាជរដ្ឋាភិបាលប្រើជាឧបករណ៍ ក្នុងគោលបំណងដើម្បីផលប្រយោជន៍ពាណិជ្ជកម្ម ហើយការផ្តល់ដីសម្បទាននេះ គឺជាការផ្តល់រង្វាន់ទៅឱ្យជនមានទ្រព្យ

ធន ដែលនាំឱ្យខាតបង់ប្រយោជន៍ធំធេងរបស់ប្រជាពលរដ្ឋសាមញ្ញ។[22] បញ្ហាវិវាទដីធ្លីនេះ បានកើតមានឡើងជាច្រើនករណី ទាំងតំបន់ទីក្រុង តំបន់ជនបទ និងតំបន់ព្រៃភ្នំ ដែលខុមប្រែ្វលបានសង្កេតឃើញ។ ការណ៍នេះ ធ្វើឱ្យមានសម្រែកពីរប្រភេទបានកើតឡើងគឺ៖

- **ប្រភេទទី១** គឺការហ៊ោកញ្ជៀវនៃក្រុមជោគជ័យទៅលើអាជីវកម្មដីធ្លី មិនថាក្រុមអ្នកធ្វើជំនួញដោយលក់ដីផ្ទាល់ ឬធ្វើជំនួញទាញប្រយោជន៍ដីទេ ពួកគេមានភាពសប្បាយក្នុងអាជីវកម្មនេះណាស់ ដោយភាពជោគជ័យនេះហើយបានធ្វើឱ្យអ្នកមានអំណាចមួយចំនួន អ្នកមានទ្រព្យធនច្រើន មានខ្សែមានខ្នងជាអ្នកមានឋានៈបុណ្យស័ក្តិមួយចំនួន ខិតខំពង្រីកនូវមុខជំនួញរបស់ខ្លួនតាមរយៈអចលនទ្រព្យនេះ ដែលក្រុមខ្លះទទួលបានដីសម្បទានសេដ្ឋកិច្ចដើម្បីធ្វើអាជីវកម្ម ក្រុមខ្លះទន្ទ្រាន់យកដីរដ្ឋមកធ្វើជាកម្មសិទ្ធិ ក្រុមខ្លះទន្ទ្រានយកដីប្រជាពលរដ្ឋ ហើយមានក្រុមខ្លះទៀតទទួលបានដីសម្បទានមិនគ្រប់គ្រាន់ថែមទាំងទន្ទ្រានយកដីរដ្ឋ និងដីពលរដ្ឋថែមទៀតផង។ មិនថាអ្នកទទួលបានដីសម្បទាន ឬទន្ទ្រានដីទេ ពួកគេតែងប្រើប្រាស់ឥទ្ធិពលលុយ និងអំណាចដើម្បីការពារពួកគេ តាមរយៈតុលាការ ក្រុមអាជ្ញាធរ ជាពិសេសក្រុមយោធា និងនគរបាលដើម្បីកាងដីធ្លី និងការពារពួកគេ។
- **ប្រភេទទី២** គឺសម្រែកទ្រហោយំរបស់ប្រជាពលរដ្ឋដែលរងគ្រោះព្រោះដីធ្លី សំឡេងនេះក៏ព្រោះតែពួកគាត់មានបញ្ហាហើយតែមិនមានអ្នកជួយដោះស្រាយពួកគាត់ ដូច្នេះជម្រើសរបស់ពលរដ្ឋមានតែតវ៉ាទៅតាមស្ថាប័នពាក់ព័ន្ធ មានទូត ក្រសួងមន្ទីរ ឬតាមបុគ្គលអ្នកមានឥទ្ធិពលពីលើបញ្ហា ឬតវ៉ាតាមមុខផ្ទះថ្នាក់ដឹកកំពូលជាដើម តែការតវ៉ាមានបញ្ហាប្រឈមជាច្រើន៖

  - ប្រឈមការចោទប្រកាន់របស់តុលាការ ជាក់ស្តែងដូចជា កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ ២០២០ មានប្រជាពលរដ្ឋចំនួន ២៣ នាក់ នៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ ត្រូវបានសាលាដំបូងខេត្តចេញដីកាកោះហៅសួរចម្លើយពាក់ព័ន្ធទំនាស់ដីធ្លីតាមបណ្តឹងរបស់លោកស្រី ហុង សួន ភរិយាឧកញ៉ា ស៊ី គង់ទ្រីវ និងបណ្តឹងរបស់ឧកញ៉ា លី យ៉ុងផាត់ ដែលចោទពួកគេថា បានធ្វើឲ្យខូចខាតដោយចេតនា ប៉ុន្តែពលរដ្ឋអះអាងថា ការចោទប្រកាន់នេះជារឿងអយុត្តិធម៌។[23]
  - ប្រឈមការជាប់ពន្ធនាគារព្រោះការតវ៉ា ជាក់ស្តែងក្នុងករណីនេះ គឺ តំណាងសហគមន៍ពីររូបក្នុងឃុំត្រពាំងព្រីង ស្រុកតំបែរ ត្រូវចាប់ខ្លួន គឺលោក ផុន ឈឿន ត្រូវបានចាប់ខ្លួន

[22] https://cchrcambodia.org/admin/media/analysis/analysis/khmer/CCHR_Updated_Briefing_Note_Land_Reform_March_2014_KHM.pdf

[23] សុទ្ធ គឹមសឿន កាសែតភ្នំពេញប៉ុស្តិ៍,ថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ២០១៩ "ពលរដ្ឋជាង ២០ នាក់ ត្រូវបានតុលាការហៅសួររឿងជម្លោះដីធ្លីជាមួយឧកញ៉ា" https://bit.ly/2kt4pQa

កាលពីថ្ងៃទី១៦ និងលោក សែម សាង ចាប់ខ្លួននៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ ពាក់ព័ន្ធនឹងរឿងជម្លោះដីធ្លី តាមការបង្គាប់របស់តុលាការខេត្តត្បូងឃ្មុំ ក្រោយពួកគេតវ៉ាក្នុងទំនាស់ដីធ្លីជាមួយក្រុមហ៊ុនចម្ការកៅស៊ូចិនឈ្មោះថា ហាម៉ឺនី វីន អ៊ិនវេសមេន។[24]

- ភរិយាសកម្មជនដីធ្លីម្នាក់ ស្វែងរកអន្តរាគមន៍ឲ្យតុលាការខេត្តត្បូងឃ្មុំដោះលែងប្តីរបស់គាត់ ឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ដើម្បីជួយសម្រាលការងារខ្លួន ខណៈដែលអ្នកស្រីកំពុងមានផ្ទៃពោះប្រាំខែ អ្នកស្រី ឈឿន សុខ ជាប្រពន្ធរបស់សកម្មជនដីធ្លី គឺ លោក សែម សាង ឲ្យដឹងថាអ្នកស្រីបានស្នើសុំមេធាវីដើម្បីដាក់ពាក្យទៅកាន់តុលាការខេត្តត្បូងឃ្មុំឲ្យដោះលែងប្តីអ្នកស្រីនៅក្រៅឃុំបណ្តោះអាសន្ន។ អ្នកស្រីអះអាងថា ការឃុំខ្លួននេះធ្វើឡើងដោយអយុត្តិធម៌ក្រោយប្តីរបស់អ្នកស្រីតវ៉ារឿងដីធ្លីជាមួយក្រុមហ៊ុនចិន ដែលមានផ្ទៃដីជាង៧០០ហិកតា។ ក្នុងដីកាចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ ចៅក្រមស៊ើបសួរសាលាដំបូងខេត្តត្បូងឃ្មុំលោក ហៃ ណៃហេង បានបង្គាប់ឲ្យនាំខ្លួនលោក សែម សាង ទៅសួរចម្លើយនៅសាលាដំបូងខេត្ត ក្រោមបទចោទ «***កំហែងយកដោយមានស្ថានទម្ងន់ទោសដោយសារប្រើប្រាស់អាវុធ***» ដែលបានប្រព្រឹត្តកាលពីឆ្នាំ២០១៦។
- បញ្ហាសុវត្ថិភាព ការគំរាមកំហែង និងចាប់ចងជាដើម ពាក់ព័ន្ធនឹងករណីនេះ គឺ កាលពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០២០ អាជ្ញាធរស្រុកព្រៃនប់ ខេត្តព្រះសីហនុ បានចាប់ខ្លួនមនុស្ស២១នាក់ យកមកសាកសួរនៅអធិការស្រុកព្រៃនប់ បន្ទាប់ពីមានករណីប៉ះទង្គិចគ្នាដោយហិង្សារវាងអាជ្ញាធរ និងប្រជាពលរដ្ឋ នៅភូមិស្មាច់ដែង ឃុំរាម ស្រុកព្រៃនប់ កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០។ អ្នកនាំពាក្យសាលាខេត្តព្រះសីហនុ លោក យាង ភារម្យ ឱ្យដឹងថា សមត្ថកិច្ចស្រុកព្រៃនប់បានសម្រេចឃាត់ខ្លួនមនុស្ស ៣នាក់ ដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការក្នុងបទចោទ«***កាន់កាប់ទ្រព្យសម្បត្តិរដ្ឋដោយខុសច្បាប់***»។[25]

ក្រៅពីតវ៉ា ប្រជាពលរដ្ឋក៏បានទៅសុំអន្តរាគមន៍ផងដែរ ពីសំណាក់ស្ថានទូតនានា ពីរដ្ឋសភា និងពីសំណាក់ប្រមុខរដ្ឋាភិបាល តាមរយៈការដាក់លិខិតឱ្យជួយអន្តរាគមន៍រកដំណោះស្រាយសម្រាប់ពួកគាត់។

---

[24] លោក ឃុត សុគន្ធ VOD, ១៨ តុលា ២០១៩ "អ្នកភូមិជាង១០០នាក់នៅខេត្តត្បូងឃ្មុំបន្តបាតុកម្មទាមទារឲ្យដោះលែងតំណាងពួកគាត់២នាក់" https://vodkhmer.news/2019/10/18/more-100-villagers-tbong-khmum-province-continue-their-protest-demanding/ និង ដោយ ប៉ាន់ បូរិន្ទ NewsRoom Cambodia, ៥ វិច្ឆិកា ២០១៩, " ភរិយាសកម្មជនដីធ្លី ស្នើតុលាការខេត្តត្បូងឃ្មុំ ដោះលែងប្តីរបស់ខ្លួនឱ្យនៅក្រៅឃុំបណ្តោះអាសន្ន" https://newsroomcambodia.com/kh/2019/11/05/newsroom-cambodia-borin-land-activist-wife-request-tbong-khmum-court-release-her-husband-on-bail/?fbclid=IwAR3tUS15sm7ZjV21BLWRRM2oYflGqJMDkcCh1-p-1k6siDxqK7EIKmUH2aQ

[25] លោក វណ្ណ វិចារ សារព័ត៌មាន វីអូឌី, ៦ មករា ២០២០ "ពលរដ្ឋ៣នាក់ត្រូវបានចាប់ខ្លួនបញ្ជូនទៅតុលាការក្នុងរឿងទំនាស់ដីធ្លីនៅខេត្តព្រះសីហនុ" https://vodkhmer.news/2020/01/06/three-villagers-sent-to-court-after-a-crackdown-on-land-dispute-in-sihanoukville/?fbclid=IwAR0iYpoXQy9dGfCvlGBphxrpNwuGFkk6060wbWDgJUsfc16R6vquOpIdkL8

- **បញ្ហាកម្មករ៖** មានការតវ៉ាជាច្រើនរបស់កម្មករ កម្មការិនី ដើម្បីទាមទារលក្ខខណ្ឌការងារសមស្រប តែមិនដែលឃើញគណៈកម្មការណាចុះពិនិត្យមើលអន្តរាគមន៍ដោះស្រាយជូនពួកគាត់ឡើយ។

## ៤.ការវិភាគសកម្មភាពរបស់តំណាងរាស្ត្រ

មានតំណាងរាស្ត្រជាច្រើនរូប ដែលបានសកម្មក្នុងប្រជុំពេញអង្គរបស់រដ្ឋសភា ក៏ដូចជាសកម្មទៅតាមមូលដ្ឋានផងដែរ តែខុមហ្វ្រែលបានជ្រើសរើសតំណាងរាស្ត្រដែលមានសកម្មភាពសកម្មជាងគេក្នុងរដ្ឋសភា ចំនួន ១០រូប លើការឡើងបញ្ចេញមតិក្នុងការអនុម័តច្បាប់ និងនៅមូលដ្ឋាន ក្នុងការចុះជួបប្រជាពលរដ្ឋ និងមន្ត្រីអាជ្ញាធរ។

### ក្រាហ្វិកទី១០ ប្រៀបធៀបសកម្មភាពតំណាងរាស្ត្របញ្ចេញមតិ និងចុះមូលដ្ឋាន




ក្រាហ្វិកខាងលើបានបង្ហាញថា តំណាងរាស្ត្រ ដែលសកម្មនៅក្នុងសម័យប្រជុំរបស់រដ្ឋសភា តែងតែឡើងបញ្ចេញមតិជារឿយៗនោះ គឺមិនបានចុះទៅមូលដ្ឋានឱ្យសស្រាក់សស្រាំនោះទេ គឺពួកគាត់ចុះបានតិចតួច ផ្ទុយគ្នាមកវិញ ចំពោះតំណាងរាស្ត្រដែលចុះទៅមូលដ្ឋានច្រើនជាងគេ ៨រូបក្នុងចំណោម ១០រូប ដែលខុមហ្វ្រែលប្រមូលព័ត៌មានបាន គឺមិនឃើញមានឡើងបញ្ចេញមតិនៅក្នុងសម័យប្រជុំរបស់រដ្ឋសភាឡើយ។

ខុមហ្វ្រែល សូមធ្វើការវិភាគលើអ្នកតំណាងរាស្ត្រ ១០រូប ដែលមានសកម្មភាព ក្នុងសម័យប្រជុំរដ្ឋសភា និងសកម្មភាពចុះមូលដ្ឋាន ដូចខាងក្រោម៖

**១. ឯកឧត្តម ឈាង វុន** តំណាងរាស្ត្រមណ្ឌលខេត្តបាត់ដំបង ជាប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាននៃរដ្ឋសភា មិនមានតួនាទីជាសមាជិករដ្ឋាភិបាលនោះទេ។ នៅក្នុងសម័យប្រជុំរដ្ឋសភាឆ្នាំទី២ នៃអាណត្តិទី៦ ឯកឧត្តមបានឡើងបញ្ចេញមតិចំនួន **៩ដង** បើគិតជាពេលវេលាគឺមានរយៈពេលចំនួន **៥៦នាទី** ក្នុងនោះ **៤នាទី** ជាមតិបែបអព្យាក្រឹត និង**៥២នាទី**ជាការបញ្ចេញមតិក្នុងន័យបែបវិជ្ជមាន។ រីឯការចុះមូលដ្ឋានវិញ ឯកឧត្តមចុះបានតែម្តងគត់ នោះគឺការសំណេះសំណាលសួរសុខទុក្ខ។

**២. ឯកឧត្តម ហ៊ុន ម៉ានី** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ស្ពឺ ជាប្រធានគណៈកម្មការអប់រំយុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍នៃរដ្ឋសភា គាត់មិនមានតួនាទីនៅក្នុងរដ្ឋាភិបាលទេ តែឯកឧត្តម ជាប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា ដែលជាស្ថាប័នក្រៅរដ្ឋាភិបាល។ ឆ្នាំទី២នេះ ឯកឧត្តម បានឡើងបញ្ចេញមតិក្នុងសម័យប្រជុំពេញអង្គរបស់រដ្ឋសភាបានចំនួន **២ដង** បើគិតជានាទីបានចំនួន**១៧នាទី** ដែលមតិទាំងអស់សុទ្ធតែជាមតិបែបវិជ្ជមាន ដូចជាការសសើរលើរដ្ឋាភិបាលក្នុងការដឹកនាំ ការសសើរលើច្បាប់ដែលរដ្ឋសភាបានអនុម័តជាដើម។

**៣.លោកជំទាវ ឡោក ខេង** តំណាងរាស្ត្រមណ្ឌលរាជធានីភ្នំពេញ និងជាប្រធានគណៈកម្មការ សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី នៃរដ្ឋសភា គាត់មិនមានតួនាទីក្នុងរដ្ឋាភិបាលទេ។ លោកជំទាវ បានចុះទៅមូលដ្ឋានបានចំនួន **៣៨ដង** ក្នុងនោះ ចុះចួបសំណេះសំណាលសួរសុខទុក្ខចំនួន **២៨ដង** ចុះក្នុងគោលបំណងពង្រឹងផ្ទៃក្នុងបក្សចំនួន **៤ដង** ចូលរួមក្នុងវេទិកាចំនួន **៥ដង** និងអមដំណើរថ្នាក់ដឹកនាំចំនួន**១ដង**។ រីឯក្នុងសម័យប្រជុំពេញអង្គរដ្ឋសភាវិញ លោកជំទាវ បានឡើងបញ្ចេញមតិបានចំនួន **៤ដង** បើគិតជានាទីគឺបាន**៣៣នាទី** ក្នុងនោះការបញ្ចេញមតិបែបអព្យាក្រិត**១៣នាទី** និងបែបវិជ្ជមាន**២០នាទី**។

**៤. លោកជំទាវ កុល ធារិន** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម ជាសមាជិកាគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា គាត់មិនមែនជាសមាជិក និងមានតួនាទីក្នុងរដ្ឋាភិបាលទេ។ ក្នុងឆ្នាំទី២ នៃអាណត្តិទី៦ នេះ លោកជំទាវ បានចុះទៅមូលដ្ឋានចួបប្រជាពលរដ្ឋ និងមន្ត្រីអាជ្ញាធរច្រើនជាងគេ គឺមានរហូតទៅដល់**៤២ដង**ឯណោះ តែចំពោះការប្រជុំនៅក្នុងរដ្ឋសភាវិញ ខុមហ្វ្រែល មិនឃើញមានលោកជំទាវឡើងបញ្ចេញមតិម្តងណាឡើយក្នុងឆ្នាំទី២នេះ។

**៥. ឯកឧត្តមវេជ្ជបណ្ឌិត សុះ មុះសិន** តំណាងរាស្ត្រមណ្ឌលកណ្តាល ជាសមាជិកគណៈកម្មការ សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី នៃរដ្ឋសភា គាត់មិនមែនជាសមាជិក និងមិនមានតួនាទីក្នុងរដ្ឋាភិបាលទេ តែគាត់មានតួនាទីនៅស្ថាប័នក្រៅរដ្ឋាភិបាល គឺជាអនុប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា និងជាប្រធាន

សមាគមគ្រូពេទ្យអ៊ីស្លាមកម្ពុជា។ ឯកឧត្តម បានចុះទៅចួបប្រជាពលរដ្ឋ និងមន្ត្រីមូលដ្ឋានបាន**៣៩ដង** (ចុះសំណេះសំណាលសួរសុខទុក្ខ៣៨ដង និងអមដំណើរថ្នាក់ដឹកនាំ១ដង) តែនៅក្នុងសម័យប្រជុំរដ្ឋសភាវិញ ខុមហ្វ្រែលមិនបានឃើញឯកឧត្តមឡើងបញ្ចេញទៅលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាមួយឡើយ។

**៦. ឯកឧត្តម ប៊ូ ឡាំ** តំណាងរាស្ត្រមណ្ឌលខេត្តរតនគិរី និងជាសមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈនៃរដ្ឋសភា គាត់មិនមានតួនាទីក្នុងរដ្ឋាភិបាលទេ តែគាត់ជាអនុប្រធានក្រុមការងារបក្សចុះមូលដ្ឋានខេត្តរតនគិរី។ ចំពោះសកម្មភាពនៅមូលដ្ឋានវិញ ឯកឧត្តម មានភាពសកម្មច្រើនទាំងការសួរសុខទុក្ខ ដោះស្រាយបញ្ហាជូនពលរដ្ឋ គឺបានចំនួន**៣៥ដង** ក្នុងនោះចុះដោះស្រាយបញ្ហាជូនពលរដ្ឋបានចំនួន**២ដង** សំណេះសំណាលសួរសុខទុក្ខចំនួន**២៩ដង** អមដំណើរថ្នាក់ដឹកនាំចំនួន**៣ដង** និងចុះពង្រឹងផ្ទៃក្នុងបក្សចំនួន**១ដង**។ នៅក្នុងសម័យប្រជុំពេញអង្គរបស់រដ្ឋសភា ឆ្នាំទី២នេះ ឯកឧត្តម មិនដែលបានឡើងបញ្ចេញមតិទេ។

**៧.ឯកឧត្តម ប៉ាល់ សំអឿន** តំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ ជាអនុប្រធានគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជនយុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី នៃរដ្ឋសភា គាត់មិនមានតួនាទីនៅក្នុងរដ្ឋាភិបាលទេ។ តំណាងរាស្ត្ររូបនេះ បានចុះទៅមូលដ្ឋានបានចំនួន**៣៤ដង** ក្នុងនោះការចុះសំណេះសំណាលសួរសុខទុក្ខបានចំនួន**២៨ដង** អមដំណើរថ្នាក់ដឹកនាំចំនួន**៥ដង** និងចុះពង្រឹងបក្សចំនួន**១ដង**។ រីឯការប្រជុំនៅក្នុងសភា ឯកឧត្តម មិនដែលឡើងបញ្ចេញមតិទៅលើសេចព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាមួយទេ។

**៨. លោកជំទាវ ស្រី គឹមឆយ** តំណាងរាស្ត្រមណ្ឌលកំពង់ចាម ជាសមាជិកាគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា នៃរដ្ឋសភា គាត់មិនមែនជាសមាជិក និងមិនមានតួនាទីក្នុងរដ្ឋាភិបាលទេ។ លោកជំទាវ បានចុះទៅមូលដ្ឋានចួបប្រជាពលរដ្ឋ និងមន្ត្រីអាជ្ញាធរបាន **៣៣ដង** ចំពោះសម័យប្រជុំនៃរដ្ឋសភាវិញ លោកជំទាវ មិនបានឡើងបញ្ចេញឡើយក្នុងឆ្នាំទី២នេះ។

**៩. លោកជំទាវ ខុង ស៊ុនអេង** តំណាងរាស្ត្រមណ្ឌលកំពង់ចាម ជាសមាជិកាគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈនៃរដ្ឋសភា គាត់មិនមានតួនាទីក្នុងរដ្ឋាភិបាលទេ។ លោកជំទាវ បានចុះទៅមូលដ្ឋានចួបប្រជាពលរដ្ឋ និងមន្ត្រីអាជ្ញាធរបាន **៣៣ដង** រីឯសម័យប្រជុំនៃរដ្ឋសភាវិញ លោកជំទាវ មិនបានឡើងបញ្ចេញឡើយក្នុងឆ្នាំទី២នេះ។ លោកជំទាវ ខុងស៊ុនអេង លោកជំទាវ ស្រី គឹមឆយ និងលោកជំទាវ កុល ធារិន ជាដៃគូរតំណាងរាស្ត្រស្ត្រីដ៏សកម្មនៅមូលដ្ឋាន ពួកគាត់ទាំងបីរូបតែងចុះទៅមូលដ្ឋានរួមគ្នា។

**១០. ឯកឧត្តម ខួយ សុខា** តំណាងរាស្ត្រមណ្ឌលខេត្តពោធិ៍សាត់ និងជាសមាជិកគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹកនៃរដ្ឋសភា គាត់មិនមានតួនាទីក្នុងរដ្ឋាភិបាលទេ តែគាត់ជាទីប្រឹក្សាជាន់ខ្ពស់របស់យុវជនស្រឡាញ់សន្តិភាពខេត្តពោធិ៍សាត់ ដែលជាស្ថាប័នមិនមែនរដ្ឋាភិបាល។ ឯកឧត្តម បានចុះទៅមូលដ្ឋាន**២៧ដង** ក្នុងនោះគាត់ដោះស្រាយបញ្ហាជូនពលរដ្ឋបាន**១ដង** សំណេះសំណាលសួរសុខទុក្ខចំនួន**១៧ដង** និងអមដំណើរថ្នាក់ដឹកនាំចំនួន**៩ដង**។ នៅក្នុងរដ្ឋសភាវិញ ឯកឧត្តម មិនដែលបានបញ្ចេញមតិក្នុងសម័យប្រជុំរបស់រដ្ឋសភាណាមួយឡើយ នៅក្នុងឆ្នាំទី២នេះ។

ការលើកយកតំណាងរាស្ត្រទាំង១០ ខាងលើមកបង្ហាញនេះ ឃើញថា មិនមានតំណាងរាស្ត្រដែលមានតួនាទីនៅក្នុងរដ្ឋាភិបាលរូបណា សស្រាក់សស្រាំ ជជែកបញ្ចេញមតិនៅក្នុងសម័យប្រជុំរបស់រដ្ឋសភា ក៏ដូចជានៅមូលដ្ឋានដែរ គឺមានតិចតួចបំផុត។ ជារួម កិច្ចការទាំងអស់ដែលជជែកដេញដោលគឺតម្រូវឱ្យអ្នកតំណាងរបស់ប្រជាពលរដ្ឋមានការតាមដាន ឬធ្វើការជិតស្និទជាមួយម្ចាស់ឆ្នោត រួមទាំងឆ្លើយតបទៅនឹងប្រយោជន៍ជាសាធារណៈនៃម្ចាស់ឆ្នោតទើបមានតម្លៃជាអ្នកតំណាង និងអាចជជែកដោយមានអំណះអំណាង។

នៅក្នុងរដ្ឋធម្មនុញ្ញ មាត្រា ៨៣ និងមានចែងនូវខ្លឹមសារដដែលក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ប្រការ ១ ថា រដ្ឋសភាប្រជុំជាសាមញ្ញចំនួនពីរដងក្នុង១ឆ្នាំ។ សម័យប្រជុំនីមួយៗ មានថិរវេលាយ៉ាងតិចបីខែ។ បើមានសេចក្តីស្នើសុំពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិករដ្ឋសភាមួយភាគបីយ៉ាងតិច គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា កោះប្រជុំរដ្ឋសភាជាវិសាមញ្ញ។ ន័យនេះ សភាបានបែងចែកកាលវេលាប្រជុំជាពីរ ដែលសរុបសម័យប្រជុំពីរដងចូលគ្នាគឺអស់ពេល៦ខែយ៉ាងតិច។ ចុះចន្លោះនៃសម័យប្រជុំនីមួយៗ តើតំណាងរាស្ត្រត្រូវសម្រាកវិសមកាលមែនទេ? ជាការពិតតំណាងរាស្ត្រត្រូវវិសមកាល ប៉ុន្តែវិសមកាលរបស់តំណាងរាស្ត្រ គឺតម្រូវឱ្យអ្នកតំណាងរបស់ប្រជាពលរដ្ឋធ្វើការតាមដាន ឬធ្វើការជិតស្និទជាមួយម្ចាស់ឆ្នោត រួមទាំងឆ្លើយតបទៅនឹងប្រយោជន៍ជាសាធារណៈនៃម្ចាស់ឆ្នោត ដោយវិសមកាលពីការប្រជុំនៅក្នុងរដ្ឋសភានេះ គ្រប់តំណាងរាស្ត្រទាំងអស់មិនថាមានតួនាទីនៅក្នុងរដ្ឋាភិបាល ឬអត់មាននោះទេ គឺតម្រូវឱ្យចុះទៅចួបដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋនៅមូលដ្ឋាន និងប្រមូលនូវបញ្ហាប្រឈម សំណើរ ឬសំណូមពររបស់ប្រជាពលរដ្ឋ។

ការចុះចួបពលរដ្ឋ គឺដើម្បីដឹងពីស្ថានភាពសុខទុក្ខ ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដោះស្រាយបញ្ហាជូនពួកគាត់ក្នុងករណីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធមិនបានបំពេញតួនាទីឱ្យសមស្របទៅនឹងតម្រូវការរបស់ពួកគាត់ និងពិនិត្យមើលលើការអនុវត្តច្បាប់របស់អាជ្ញាធរមូលដ្ឋានផងដែរ មិនត្រឹមតែប៉ុណ្ណោះ តំណាងរាស្ត្រក៏ត្រូវប្រមូលនូវបញ្ហារបស់ពលរដ្ឋទៅរាយការណ៍ និងជជែកដេញដោលនៅក្នុងរដ្ឋសភាផងដែរ ហើយក្នុងករណីបញ្ហាប៉ះពាល់ធ្ងន់ធ្ងរដល់ប្រយោជន៍ប្រជាពលរដ្ឋ និងប្រយោជន៍ជាតិ តំណាង

រាស្ត្រក៏អាចកោះអញ្ជើញតស្សូរជនក្នុងរដ្ឋាភិបាលមកឆ្លើយបំភ្លឺផងដែរ ។ ដូច្នេះនៅក្នុងសម័យប្រជុំនៅរដ្ឋសភា អ្នកតំណាងរាស្ត្រអាចលើកបញ្ហាចោទសួរដោយផ្ទាល់ ឬលាយលក្ខណ៍អក្សរ ឱ្យមន្ត្រីរដ្ឋាភិបាលបកស្រាយចំពោះការការអនុវត្តន៍ច្បាប់ ឬឆ្លើយតបពីបញ្ហាអ្វីមួយដែលម្ចាស់ឆ្នោតបានជួបប្រទះនោះ។ ប៉ុន្តែជាក់ស្តែងមានតំណាងរាស្ត្រតែប៉ុន្មានរូបប៉ុណ្ណោះដែលបានឡើងបញ្ចេញមតិនៅក្នុងអង្គប្រជុំរដ្ឋសភា និងបានចុះទៅមូលដ្ឋាន។ ការចុះទៅមូលដ្ឋានទៀតសោត ក៏មិនបានយកបញ្ហាដែលកើតមាននៅមូលដ្ឋានមករាយការណ៍ជូនរដ្ឋសភាដែរ គឺរាយការណ៍តែពីចំនួននៃការចុះ តែចំនួននៃបញ្ហាជាក់ស្តែងរបស់ប្រជាពលរដ្ឋគឺគ្មានអ្នកតំណាងរាស្ត្ររូបណារាយការណ៍ទាល់តែសោះ។

## ៥.សកម្មភាពរបស់តំណាងរាស្ត្រក្នុងស្ថានភាពកូវីដ-១៩

ចុងឆ្នាំ២០១៩ ជាឆ្នាំដែលពិភពលោក ក្នុងនោះមានទាំងកម្ពុជាផង បានចាប់ផ្តើមរងគ្រោះដោយជំងឺរាតត្បាតកូវីដ-១៩ រហូតមកដល់បច្ចុប្បន្ននៅតែមិនទាន់ស្រាកស្រាន្ត។ ក្នុងស្ថានភាពបែបនេះ មិនថា ពលរដ្ឋ ឬមន្ត្រីរាជការ ឬអ្នកតំណាងរាស្ត្រទេ គឺមានភាពភ័យខ្លាចយ៉ាងខ្លាំង ព្រោះជាជំងឺដែលអ្នកស្រាវជ្រាវមិនទាន់បង្កើតថ្នាំព្យាបាលបាន។

បើទោះជាមានកូវីដ-១៩ក៏ដោយ ក៏តំណាងរាស្ត្រនៅតែមានសកម្មភាពទាំងការចូលរួមក្នុងសម័យប្រជុំ ទាំងការចុះទៅមូលដ្ឋាន។

– **សកម្មភាពសម័យប្រជុំរបស់រដ្ឋសភា៖**

មិនថាសម័យប្រជុំពេញអង្គរបស់រដ្ឋសភាជាសាមញ្ញសាធារណៈ ឬវិសាមញ្ញសាធារណៈទេ ឆ្នាំទី២ នៃនីតិកាលទី៦នេះ ក្នុងដំណាក់កាលនៃការរីករាលដាលជំងឺកូវីដនេះ អ្នកតំណាងរាស្ត្រនៅតែចូលរួមគ្រប់កូរ៉ុមនៃសម័យប្រជុំពេញអង្គរដ្ឋសភាដដែល ហើយសម័យប្រជុំនីមួយៗក៏មិនមានរឿងចម្រូងចម្រាសដូចឆ្នាំទី២ នៃអាណត្តិមុនៗដែរ។ តាមការសង្កេតរបស់ខុមហ្វ្រែលមើលឃើញថាក្នុងពេលដំណើរការសម័យប្រជុំដើម្បីពិភាក្សាពីសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នីមួយៗ មិនខុសអ្វីពីពេលមិនមានជំងឺកូវីដឡើយ។ គ្រាន់តែកិច្ចប្រជុំក្នុងស្ថានភាពកូវីដ តំណាងរាស្ត្រចូលប្រជុំដោយធ្វើការអនុវត្តិតាមគោលការណ៍សុខភាពដែលក្រសួងសុខាភិបាលបានណែនាំ។

– **ការចុះទៅមូលដ្ឋាន៖**

កូវីដ-១៩ គឺជាជំងឺដែលវាស់ពីកម្រិតនៃទឹកចិត្តរបស់តំណាងរាស្ត្រក្នុងការគិតគូពីសុខទុក្ខរបស់ប្រជាពលរដ្ឋ។ មានអ្នកតំណាងរាស្ត្រខ្លះមិនដែលបានចុះទៅមូលដ្ឋានសោះ រីឯតំណាងរាស្ត្រខ្លះទៀតមានការសស្រាក់សស្រាំខ្វាត់ខ្វែងក្នុងការចុះទៅមូលដ្ឋាន។ ទោះជាយ៉ាងណាតំណាងរាស្ត្រចុះទៅមូលដ្ឋាន ពួកគាត់តែងតែលើកឡើងពីបញ្ហាកូវីដ-១៩ និងណែនាំប្រជាពលរដ្ឋឱ្យគោរពតាមវិធានការណែនាំរបស់ក្រសួងសុខាភិបាល ហើយត្រូវមានភាពប្រុងប្រយ័ត្នខ្ពស់រក្សា

គម្លាតពីគ្នា មិនត្រូវនៅចួបជុំគ្នា នេះជាអ្វីដែលតំណាងរាស្ត្រចុះមូលដ្ឋានក្នុងស្ថានភាពកូវីដតែងតែធ្វើ បន្ថែមពីនោះគាត់តែងតែផ្សាភ្ជាប់នូវសម្ភារៈការពារកូវីដសម្រាប់ចែកជូនប្រជាពលរដ្ឋ និងអំណោយផ្សេងទៀតផងដែរ។

## ៦. កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗ នៃរដ្ឋសភាជាតិ

## សម័យប្រជុំលើកទី២ នីតិកាលទី៦

## (ចន្លោះពីខែកញ្ញា ឆ្នាំ២០១៩ ដល់ខែសីហា ឆ្នាំ២០២០)

- **ថ្ងៃទី ០៤ ខែតុលា ឆ្នា២០១៩ រដ្ឋសភាបើកសម័យប្រជុំលើកទី៣ ដោយអនុម័តរបៀបវារៈចំនួន៧៖**

១. ព្រះរាជសារព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជូនសម័យប្រម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦។

២. របាយការណ៍ស្តីពី សកម្មភាពរបស់រដ្ឋសភា ចន្លោះសម័យប្រជុំរដ្ឋសភាលើកទី២ និងទី៣ នីតិកាលទី៦។

៣. ការពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងអង្គការហាមឃាត់អាវុធគីមី ស្តីពី បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អង្គការហាមឃាត់អាវុធគីមី។

៤. ការពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពី សំណង់

៥. ការពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច។

៦. ការពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់។

៧. ការពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពី របបសន្តិសុខសង្គម។

- **ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៩ រដ្ឋសភាបើកសម័យប្រជុំពេញអង្គលើកទី៣ ដោយអនុម័តនូវរបៀប វារៈ ចំនួន៥៖**

១. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាបំពេញបន្ថែម លើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម។

២. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា និងនិងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេស ហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពី ការជៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្លំពន្ធ ពាក់ព័ន្ធនឹងពន្ធលើប្រាកក់ចំណូល។

៣. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី២ ស្តីពីការកំណត់ច្រកទ្វារព្រំដែនឆ្លងកាត់នៃកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ាន ស្តីពីកិច្ចសម្របសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់។

៤. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ាន ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច។

៥. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃកិច្ចព្រមព្រៀងក្របខណ្ឌ ស្តីពីការបង្កើតសម្ព័ន្ធភាពថាមពលព្រះអាទិត្យអន្តរជាតិ។

- **ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ រដ្ឋសភាបើកសម័យប្រជុំពេញអង្គលើកទី៣ ដោយអនុម័តនូវរបៀបវារៈចំនួន៣៖**

១. សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។

២. សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨។

៣. សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩ នៃច្បាប់ស្តីពី សហជីព ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦។

- **ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ រដ្ឋសភាបើកសម័យប្រជុំពេញអង្គលើកទី៣ ដោយអនុម័តនូវរបៀបវារៈចំនួន៧៖**

១. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃកិច្ចព្រមព្រៀងសម្រាប់អនុវត្តបទបញ្ញត្តិនៃអនុសញ្ញា សហប្រជាជាតិស្តីពី ច្បាប់សមុទ្ទ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ ទាក់ទងនឹងការគ្រប់គ្រង និងការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ។

២. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ហ្គ្រីនណឺស្ទែនណឺប៊ិល វេនឈ័រ(ខេមបូឌា) ឯ.ក. សម្រាប់គម្រោងសាងសង់ស្ថានីយ៍ផលិតអគ្គិសនី ដើរដោយពន្លឺព្រះអាទិត្យ អានុភាព២០មេហ្គាវ៉ាត់ នៅខេត្តស្វាយរៀង។

៣. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន វ៉ាយ ផៅវ័រ ស៊ឺបផ្លាយ ឯ.ក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតអគ្គិសនី ដើរដោយពន្លឺព្រះអាទិត្យ អានុភាព៣០មេហ្គាវ៉ាត់ នៅខេត្តបន្ទាយមានជ័យ។

៤. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន វ៉ាយ សិនអេនើជី (ខេមបូឌា) បាត់ដំបង ឯ.ក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតអគ្គិសនី ដើរដោយពន្លឺព្រះអាទិត្យ អានុភាព៦០មេហ្គាវ៉ាត់ នៅខេត្តបាត់ដំបង។

៥. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្មេថេក អ៊ីនហ្វីនីត ឯ.ក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ អានុភាព៣០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

៦. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ធីអេសប៊ីភី សេកុង ផៅវ័រ អ៊ែនមីនើរ៉ល ខមភេនី លីមីតធីត នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

៧. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន សេកុង សឹមម័ល ផៅវ័រ ផ្លេន ខមភេនី លីមីតធីត នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

**ចន្លោះសម័យប្រជុំពេញអង្គលើកទី៣ និងទី៤ នៃឆ្នាំទី២ អាណត្តិទី៦ (ប្រជុំវិសាមញ្ញ)**

- **ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ រដ្ឋសភាបើកសម័យប្រជុំវិសាមញ្ញពេញអង្គ ដោយអនុម័តនូវរបៀបវារៈចំនួន៦៖**

១. សេចក្តីព្រាងច្បាប់ស្តី ការបង្កើតក្រសួង ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

២. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី២ ស្តីពី វិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។

៣.សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសាទី៣ ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។

៤. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី១ ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន។

៥. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី ការផ្ទេរទណ្ឌិតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

៦. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

- **ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ រដ្ឋសភាបើកសម័យប្រជុំវិសាមញ្ញពេញអង្គ ដោយអនុម័តនូវរបៀបវារៈចំនួន៣៖**

១. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាសជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន រ៉ូយ៉ាល់គ្រុប អ៊ិនវេសម៉ិន គ្រុប ឯ.ក សម្រាប់គម្រោងវិនិយោគសាងសង់រោងចក្រអគ្គិសនីដុតធ្យូងថ្ម អានុភាព៧០០មេហ្គាវ៉ាត់ ខេត្តកោះកុង។

២. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាសជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ហាន សេង ខូលម៉ាញ សម្រាប់គម្រោងវិនិយោគសាងសង់រោងចក្រអគ្គិសនីដុធ្យូងថ្ម អានុភាព២៦៥មេហ្គាវ៉ាត់ ខេត្តឧត្តរមានជ័យ។

៣. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាសជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ហាន សេង ខូល ម៉ាញ សម្រាប់គម្រោងវិនិយោគសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនីតង់ស្យុង២៣០គីឡូវ៉ុល តភ្ជាប់ពីរោងចក្រអគ្គិសនីដុតធ្យូងថ្ម ខេត្តឧត្តរមានជ័យ មកអនុស្ថានីយសៀមរាបខាងកើត។

- **ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ រដ្ឋសភាបើកសម័យប្រជុំវិសាមញ្ញពេញអង្គ ដោយអនុម័តនូវរបៀបវារៈចំនួន១៖**

១. ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត លើការតែងតាំង និងកែសម្រួសមាសភាពរាជរដ្ឋាភិបាល

ក.តែងតាំងទេសរដ្ឋមន្ត្រីៈ

- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ជាទេសរដ្ឋមន្ត្រី
- ឯកឧត្តម ហឹម ឆែម ជាទេសរដ្ឋមន្ត្រី(ទទួលបន្ទុកបេសកកម្មពិសេស)
- ឯកឧត្តម អង្គ វង្សវឌ្ឍានា ជាទេសរដ្ឋមន្ត្រី(ទទួលបន្ទុកបេសកកម្មពិសេស)
- ឯកឧត្តម ត្រាំ អ៊ីវតឹក ជាទេសរដ្ឋមន្ត្រី(ទទួលបន្ទុកបេសកកម្មពិសេស)
- ឯកឧត្តម ពេជ្រ ប៊ុនធិន ជាទេសរដ្ឋមន្ត្រី(ទទួលបន្ទុកបេសកកម្មពិសេស)

ខ.កែសម្រួល និងតែងតាំសមាសភាពរដ្ឋមន្ត្រី

- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ជារដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។
- ឯកឧត្តម កើត រិទ្ធ ជារដ្ឋមន្ត្រីក្រសួង យុត្តិធម៌
- ឯកឧត្តម ជា វ៉ានដេន ជារដ្ឋមន្ត្រីក្រសួង ប្រៃសនីយ៍ និងទូរគមនាគមន៍
- ឯកឧត្តម ឈិត សុខុន ជារដ្ឋមន្ត្រីក្រសួង ធម្មការ និងសាសនា
- ឯកឧត្តម ព្រុំ សុខា ជារដ្ឋមន្ត្រីក្រសួង មុខងារសាធារណៈ

- **ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ រដ្ឋសភាបើកសម័យប្រជុំពេញអង្គលើកទី៤ ដោយអនុម័តនូវរបៀបវារៈចំនួន២៖**

១. ការសម្រេចអំពីសុពលភាពនៃអាណត្តិរបស់លោកជំទាវ នូ សុវណ្ណនី ជាតំណាងរាស្ត្រមណ្ឌលតាកែវ ជំនួសឯកឧត្តម ជា វ៉ានដេត ដែលសុំលាលែង។

២. សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។

៣. ការបោះឆ្នោតៈ

- ឯកឧត្តម ឡូយ សុផាត ជាសមាជិកគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក។
- ឯកឧត្តម ស៊ូ ភិរិន្ទ ជាសមាជិកគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម។

- **ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ រដ្ឋសភាបើកសម័យប្រជុំពេញអង្គលើកទី៤ ដោយអនុម័តនូវរបៀប វារៈ ចំនួន៤៖**

  ១. ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

  ២. ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

  ៣. ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។

  ៤. ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាទីក្រុងប៊ែន ស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រ និងសិល្បៈឆ្នាំ១៨៨៦ និងវិសោធនកម្មឆ្នាំ១៩៧៩។